# មគ្គុទេសក៍ណែនាំស្តីពី បរិយាបន្នការងារសម្រាប់ ជនមានពិការភាព

## Guides on Inclusive Employment for People with Disabilities

ឆ្នាំ ២០២៣

# មាតិកា


**មាតិកា........................................................................................................ ២**
**បុព្វកថា...................................................................................................... ៣**
**បញ្ជីអក្សរកាត់.............................................................................................. ៤**
**ជំពូកទី១៖ ការស្វែងយល់អំពីពិការភាព...................................................................... ៥**
១.១ គោលបំណង........................................................................................ ៥
១.២ តើអ្វីទៅជាពិការភាព?............................................................................. ៥
១.៣ ផ្នត់គំនិតនៃពិការភាព.............................................................................. ៥
១.៤ ប្រភេទសំខាន់ៗនៃពិការភាព...................................................................... ៨
១.៥ ឧបសគ្គចំពោះបរិយាបន្នពិការភាព............................................................. ១៦
**ជំពូកទី ២៖ ការងារ និងជនមានពិការភាព................................................................ ១៨**
២.១ ហេតុអ្វីបានជាបរិយាបន្នការងារសំខាន់....................................................... ១៩
២.២. ក្របខ័ណ្ឌច្បាប់សម្រាប់បរិយាបន្នការងារសម្រាប់ជនពិការភាព.............................. ២១
**ជំពូកទី៣៖ ការបង្កើតអោយមានបរិយាកាសការងារ ប្រកបដោយបរិយាបន្ន........................ ២៨**
៣.១ ការសម្របសម្រួលសមរម្យនិងការបង្ក លក្ខណៈងាយស្រួលនៅកន្លែងការងារ.....២៨
៣.២ គោលការណ៍កន្លែងការងារនិងការអនុវត្តដែលជម្រុញបរិយាបន្ន.......................... ៣៣
**៤. ការជ្រើសរើសបុគ្គលិកដែលមានពិការភាព.......................................................... ៣៧**
៤.១ ដំណើរការជ្រើសរើសបុគ្គលិកប្រកបដោយបរិយាបន្នពិការភាព.............................៣៧
**៥. ករណីសិក្សានៃបរិយាបន្នការងារក្នុងក្រុមហ៊ុនឯកជនក្នុងស្រុកមួយ..............................** ៤០
**ឧបសម្ព័ន្ធទី ១ បញ្ជីស្ថាប័នដែលធ្វើការលើពិការភាពនៅកម្ពុជា........................................ ៤៨**

# បុព្វកថា

មគ្គុទេសន៍ណែនាំនេះគឺមានគោលដៅផ្តល់អោយនយោជក ប្រធានគ្រប់គ្រងផ្នែកធនធានមនុស្ស មន្ត្រីផ្នែកបរិយាបន្នពិការភាព និងអ្នកបង្កើតគោលនយោបាយដែលចូលរួមព្រាង និងអនុវត្តគោលនយោបាយការងារ។ មគ្គុទេសន៍នេះមានគោលបំណងកំណត់នូវឧបសគ្គទាំងឡាយដែលអាចនឹងកើតមានក្នុងវិស័យការងារសម្រាប់ជនមានពិការភាព។ មគ្គុទេសន៍នេះផ្តល់នូវគំនិតជាក់ស្តែងនិងយុទ្ធសាស្រ្តសម្រាប់បង្កើតអោយមានវប្បធម៌នៃកន្លែងការងារប្រកបដោយបរិយាបន្ន។ តាមរយៈការប្រើប្រាស់មគ្គុទេសន៍ណែនាំនេះ នយោជក និងអ្នកបង្កើតគោលនយោបាយអាចកែប្រែនូវវិសមភាពនិងជម្រុញអោយមានការចូលរួមពេញលេញពីជនមានពិការភាពនៅក្នុងវិស័យការងារ។

មគ្គុទេសន៍ណែនាំនេះត្រូវបានបង្កើតឡើងដោយផ្អែកលើគោលការណ៍ណែនាំដែលបានមកពីលទ្ធផលនៃកិច្ចប្រជុំក្រុមការងារបច្ចេកទេសលើបរិយាបន្នការងារ ដែលបានប្រារព្ធឡើងប្រចាំឆ្នាំនៅក្នុង ខែតុលា ឆ្នាំ២០២២ និង ២០២៣ ដោយបូករួមទាំងកិច្ចប្រឹក្សាបន្តជាមួយដៃគូមកពីស្ថាប័នពាក់ព័ន្ធដូចជា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងអប់រំ យុវជន និងកីឡា និងអង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នឯកជនជាច្រើនទៀត។

# បញ្ជីអក្សរកាត់

ADG សាខាក្រុមហ៊ុន អ៊ែដ្យាយល៍ ឌីវឡុមមិន គ្រុប ភីធីវ៉ាយ អិលធីឌី

PwDs ជនមានពិការភាព

WEDs ស្ត្រីមានពិការភាព

MOLVT ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

MOSVY ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

RECU R = ការទៅដល់ (Reach), E = ការចូលក្នុង (Enter), C = ការផ្លាស់ទី (Circulation),

U = ការប្រើប្រាស់ (Usage)

CSO អង្គការសង្គមស៊ីវិល

NGO អង្គការមិនរកប្រាក់ចំនេញ

DEI ភាពចម្រុះ សមធម៌ និងបរិយាបន្ន

ILO អង្គការអន្តរជាតិខាងការងារ

# ជំពូកទី១៖ ការស្វែងយល់អំពីពិការភាព

## ១.១ គោលបំណង

មុនពេលចាប់ផ្តើមកិច្ចខិតខំប្រឹងប្រែងដើម្បីសម្រេចឱ្យបានបរិយាបន្ន វាចាំបាច់ណាស់ក្នុងការមានការយល់ដឹងជា មូលដ្ឋានអំពីពិការភាព។ ផ្នែកនេះនឹងណែនាំអំពីគោលគំនិត និងនិយមន័យសំខាន់ៗនៃពិការភាព និង ផ្នត់គំនិតនៃពិការភាព ដែលបង្ហាញពីរបៀបដែលយើងត្រូវយល់ដឹង អំពីការកំណត់ឧបសគ្គដែលជនមានពិការភាពជួបប្រទះនៅក្នុងសង្គម។ ជំពូកនេះមានគោលបំណង ផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់ការរៀនសូត្របន្ថែម និងការគិតប្រកបដោយការស្តាបនាអំពីបញ្ហាទាក់ទងនឹងពិការភាព។

## ១.២ តើអ្វីទៅជាពិការភាព?

**អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ (UNCRPD)** ទទួលស្គាល់ ពិការភាពជាទស្សនទានដែលមានការវិវត្ត ហើយចែងថា៖

"**ជនមានពិការភាព** សំដៅលើអ្នកទាំងឡាយ ដែលមានភាពអន់ខ្សោយរយៈពេលយូរ ផ្នែកកាយសម្បទា ផ្លូវចិត្ត ប្រាជ្ញា ឬ វិញ្ញាណដែលនៅពេលជួបប្រទះឧបសគ្គនានា អាចរារាំងពួកគេមិនឱ្យមានការចូលរួមយ៉ាងពេញលេញ និងមានប្រសិទ្ធភាពក្នុងសង្គម ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ"។

**ពិការភាព = កម្សោយ + ឧបសគ្គ**

## ១.៣ ផ្នត់គំនិតនៃពិការភាព

ផ្នត់គំនិតនៃ «ពិការភាព» កំពុងតែមានការផ្លាស់ប្តូរ ហើយយើងត្រូវបន្តធ្វើការងារនេះតទៅមុខទៀត។ តាមការគិតបែបប្រពៃណី ក្រុមជនដែលមានពិការភាពត្រូវបានកំណត់លក្ខណៈដោយអ្វីដែលពួកគេមិនអាចធ្វើបាន។ ការគិតបែបនេះនាំឱ្យពួកគេទទួលរងនូវភាពព្រងើយកន្តើយ

ហើយលើសពីនោះ ត្រូវបានអ្នកដទៃរើសអើងដោយសកម្មផងដែរ។ ទស្សនទានបែបនេះ ត្រូវបានគេហៅថាគំរូបែប “ប្រពៃណី” ឬ “សប្បុរសធម៌” និង “គំរូបែបវេជ្ជសាស្ត្រ” នៃពិការភាព។

ប៉ុន្តែវិធីសាស្ត្រដែលល្អប្រសើរ ក្នុងការកំណត់អត្តសញ្ញាណពិការភាពគឺជាការធ្វើអន្តរកម្មរបស់បុគ្គលជាមួយនឹងសង្គមរបស់ពួកគេ។ គំរូនេះជាការផ្លាស់ប្តូរការផ្តោតលើបញ្ហាបុគ្គល ហើយដាក់បន្ទុកនោះទៅលើសង្គមវិញ ដែលត្រូវបានគេហៅថា “គំរូសង្គម” នៃពិការភាព។ គំរូសង្គមនេះហើយ ដែលជាវិធីសាស្ត្រដ៏ល្អ ដើម្បីឱ្យមនុស្សគ្រប់រូបចូលរួមគាំទ្រដល់ពិការភាព។

- **គំរូសប្បុរសធម៌**

ការយល់ថាបុគ្គលដែលមិនអាចដើរ ឬមើលឃើញ ពួកគេត្រូវការជំនួយផ្នែកសប្បុរសធម៌ដូចជា ការអាណិតអាសូរ ការពឹងពាក់ និងការផ្តល់ប្រាក់ឧបត្ថម្ភផ្សេងៗ។

គំរូទាំងនេះអាចធ្វើឱ្យសង្គមមិនអើពើនឹងទំនួលខុសត្រូវ ដោយពួកគេគិតថាមានអ្នកផ្សេងទៀត នឹងចូលមកដោះស្រាយក្នុងលក្ខណៈជាសប្បុរសធម៌ ហើយពួកគេមិនចាំបាច់ធ្វើអ្វីក្រៅពីនេះទៀតទេ។ ការយល់ឃើញនោះគឺជនមានពិការភាពជាប្រភពនៃបញ្ហា មិនមែនមកពីសង្គមមិនបានរាប់បញ្ចូលបុគ្គលនោះទេ តែដោយសារបុគ្គលនោះមិនមានសមត្ថភាពក្នុងការឱ្យគេដាក់បញ្ចូលខ្លួនទៅក្នុងសង្គម។

ទាំងនេះហើយដែលនាំឱ្យជនដែលមានពិការភាពគិតថាខ្លួនគាត់មានអ្វីមួយដែលមិនប្រក្រតី។ សាកស្រមៃថា អ្នកតែងតែត្រូវបានគេប្រាប់ថា អ្នកគឺជាបញ្ហាដែលតែងតែត្រូវការដំណោះស្រាយ។ ហើយមិនមែនត្រឹមតែមនុស្សម្នាក់ប៉ុណ្ណោះទេ ដែលមកប្រាប់អ្នកថាអ្នកជាបញ្ហា ប៉ុន្តែ

គំរូវេជ្ជសាស្ត្រនៃពិការភាព



សង្គមទាំងមូលផងដែរ។ បន្ទាប់ពីឮហើយ តើអ្នកមានទំនុកចិត្តដែរឬទេ? តើអ្នកមានផាសុកភាពនៅក្នុងសហាគមន៍ឬសង្គមរបស់អ្នកដែរឬទេ?

- **គំរូបែបវេជ្ជសាស្ត្រនៃពិការភាព**

ទស្សនៈនៃការមើលឃើញនៃគំរូនេះ យល់ឃើញថា ពិការភាពជារឿងរបស់បុគ្គលម្នាក់ៗដែលមានបញ្ហា សុខភាពដែលត្រូវការការព្យាបាល ឬទប់ស្កាត់។ ប្រសិន បើពិការភាពរបស់ពួកគេមិនអាចលុបបំបាត់ បានទេ នោះបុគ្គលទាំងនេះក្លាយជា “បញ្ហាសប្បុរសធម៌”។ ពួកគេត្រូវបាន ចាត់ថ្នាក់ថា ជាមនុស្ស “អកុសល” ដែលត្រូវការការអាណិតអាសូរ និងការទទួលបានសេវាសប្បុរសធម៌។

គំរូបែបវេជ្ជសាស្ត្រ ផ្តោតសំខាន់លើអ្វីដែលជនមានពិការភាពមិនអាចធ្វើបានដោយសារតែកម្សោយរបស់ពួកគេ។ ដូច្នេះដើម្បីដោះស្រាយនូវកម្សោយរបស់ពួកគេ យើងត្រូវការ ការផ្តល់ជាសម្ភារៈ ឬឧបករណ៍ (រទេះរុញ ជើង ឬដៃសិប្បនិមិត្ត វ៉ែនតា ឈើវាស ឈើច្រត់) និងការមើលថែផ្សេងៗ។

**ឧទាហរណ៍៖** នាងមិនអាចដើរបានទេ ដូច្នេះនាងត្រូវការរទេះរុញ។

- នាងមិនអាចមើលឃើញបានទេ ដូច្នេះនាងត្រូវការជំនួយការ។
- នាងមិនអាចស្តាប់បានទេ ដូច្នេះនាងត្រូវការឧបករណ៍ជំនួយការស្តាប់។

- **គំរូបែបសង្គមនៃពិការភាព**




ចាប់កំណើតនៅទសវត្សឆ្នាំ ១៩៦០ គំរូសង្គមនៃពិការភាពមានភាពខុសគ្នាខ្លាំង ដែលចែងថាពិការភាពគឺជាលទ្ធផលរបស់មនុស្ស ដែលមានបញ្ហាចុះខ្សោយក្នុងការធ្វើអន្តរកម្មនៅក្នុងបរិស្ថាន និងបរិបទសង្គម។ ពិការភាពមិនមែនជាការចុះខ្សោយដែលមានផលវិបាក មិនអាចចៀសផុតបាននោះទេ ប៉ុន្តែវាបណ្តាលមកពីរបៀបដែលសង្គមដំណើរការនិងរៀបចំ។ ភាពចុះខ្សោយអាចយល់បានតាមលក្ខណៈរូបរាងកាយរបស់មនុស្ស។ ឧទាហរណ៍៖

- មនុស្សម្នាក់មានការពិបាកក្នុងការដើរ។

- មនុស្សម្នាក់មានការពិបាកក្នុងការមើល។

ឧបសគ្គមួយកើតឡើងគឺ នៅពេលដែលសង្គមមិនអាចផ្តល់នូវវិធានការគ្រប់គ្រាន់ដើម្បីដាក់បញ្ចូលមនុស្សម្នាក់ដែលមានកម្សោយ។ នៅពេលមនុស្សម្នាក់ដែលពិបាកក្នុងការដើរត្រូវប្រឈមនឹងជណ្តើរ ពួកគេត្រូវស្ថិតក្នុងស្ថានភាពមានពិការភាព។ នៅពេលមនុស្សម្នាក់ដែលពិបាកក្នុងការមើលត្រូវប្រឈមមុខនឹងអត្ថបទដែលមានតួរអក្សរតូចៗពណ៌ស្រាលពួកគេស្ថិតក្នុងស្ថានភាពមានពិការភាព។

- មនុស្សម្នាក់ដែលពិបាកក្នុងការដើរ ផ្តល់ឱ្យពួកគេនូវជម្រាលផ្លូវឡើងមួយ។
- មនុស្សម្នាក់ដែលមានការពិបាកក្នុងការមើលផ្តល់ឱ្យពួកគេនូវឯកសារដែលងាយស្រួលអាន ( អត្ថបទមានតួរអក្សរធំៗ ពុម្ពអក្សរសាមញ្ញនិងពណ៌ដិត)។

យោងតាមបរិបទខាងលើ សង្គមគឺជាប្រភពនៃពិការភាពហើយវាងាយស្រួលណាស់ក្នុងការសង្កេតមើល

- គ្មានជម្រាលផ្លូវឡើង = រទេះរុញមិនអាចឡើងបាន = មិនមានលទ្ធភាពចូលក្នុងអាគារ **= ការមិនដាក់បញ្ចូលជនដែលមានពិការភាព**
- ពិបាកក្នុងការអានឯកសារ = មិនបានអានឯកសារ = គ្មានចំណេះដឹង **= ការមិនដាក់បញ្ចូលជនដែលមានពិការភាព**

## ១.៤ ប្រភេទសំខាន់ៗនៃពិការភាព

ការកំណត់និយមន័យ **"ពិការភាព"** គឺមានលក្ខណៈស្មុគស្មាញ ប៉ុន្តែវិធីសាស្ត្រក្នុងការយល់អំពីពិការភាពនោះ គឺការបែងចែកប្រភេទពិការភាពជា ៥ ប្រភេទ។[1]

| សម្គាល់៖ មនុស្សអាចមានកម្សោយច្រើនយ៉ាងក្នុងពេលតែមួយ។ |
| --- |

### ១.៤.១ ពិការភាពកាយសម្បទា

ពិការភាពកាយសម្បទានេះ រាប់បញ្ចូលទាំងកម្សោយមុខងារសរីរាង្គ ចលករនិង/ឬការបំលាស់ទី។ ទាំងនេះអាចមានការបម្រែបម្រួលឬភាពមិនប្រក្រតីនៃប្រព័ន្ធភាពសាំ មានភាពរីក

[1] យោងតាមគោលការណ៍ណែនាំអំពីការកំណត់អត្តសញ្ញាណពិការភាពតាមគំរូសង្គមនិងសិទ្ធិជាមូលដ្ឋានរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខែសីហា ២០២០

លូតលាស់ ឬមិនលូតលាស់ ពេលខ្លះអាចមើលឃើញឬក៏មើលមិនឃើញជូនកាលមានភាពឈឺចាប់ខ្លាំង ឈឺចាប់តិចតួច និងមិនមានការឈឺចាប់ទាល់តែសោះក៏មាន។

**កម្សោយមានភាពលូតលាស់ (Progressive)** ៖ កម្សោយទាំងនេះកាន់តែយ៉ាប់យ៉ឺនទៅៗទៅតាមពេលវេលា ប៉ុន្តែវាអាចប្រែប្រួលបានតាមភាពជាក់ស្តែង៖

- ជម្ងឺក្រិន (Multiple Sclerosis) បណ្តាលមកពីកង្វះជីវជាតិនៃប្រព័ន្ធសរសៃប្រសាទ។
- ជម្ងឺសាច់ដុំ (Muscular Dystrophy) បណ្តាលមកពីបញ្ហាសាច់ដុំ សាច់ដុំមិនដំណើរការ។
- ជម្ងឺរលាកសន្លាក់រ៉ាំរ៉ៃ (Chronic Arthritis)។

**កម្សោយមិនមានភាពលូតលាស់ (Non-Progressive)៖** កម្សោយទាំងនេះនឹងមិនមានការលូតលាស់នោះទេ ហើយមានស្ថេរភាព។

- ការប៉ះពាល់ចលករខួរក្បាល (Cerebral Palsy)៖ សំដៅលើការអភិវឌ្ឍខួរក្បាល រួមទាំងពិការភាពហ្សែន ភាពខុសប្រក្រតីនៃខួរក្បាលដែលបណ្តាលឱ្យពិការខួរក្បាល។
- ការប៉ះពាល់ខួរឆ្អឹងខ្នង (Spina Bifida)៖ អាចបណ្តាលមកពីការខូចទ្រង់ទ្រាយពីកំណើត នៃខួរឆ្អឹងខ្នង ឬក៏ប៉ះពាល់ដល់ស្រោមខួរ ដែលកត្តាទាំងនេះអាចបណ្តាល ឱ្យមានពិការភាពដល់អវយវៈក្រោម។
- របួសខួរឆ្អឹងខ្នង (Spinal Cord Injury)៖ សំដៅលើការខូចខាតសរសៃប្រសាទដែលបណ្តាលមកពីការរងរបួសឆ្អឹងខ្នង ការខូចខាតដល់ឆ្អឹងខ្នង សរសៃចង ឬថាសនៃជួរឈរឆ្អឹងខ្នង ឬការប៉ះពាល់នៃផ្នែកណាក្នុងចំណោមនេះ។

ប៉ុន្តែកម្សោយខាងក្រោមនេះគឺមិនមានការលូតលាស់ទេ តែអាចមានការប្រែប្រួល៖

- ស្ពានភាពឈឺចាប់រ៉ាំរ៉ៃ (Fibromyalgia)៖ បណ្តាលឱ្យមានការឈឺចាប់សាច់ដុំ សរសៃពួរ និងសន្លាក់។ វាក៏ត្រូវបានកំណត់លក្ខណៈដោយការគេងមិនលក់ អស់កម្លាំង ការថប់អារម្មណ៍ ការបាក់ទឹកចិត្ត និងការរំខានដល់មុខងារពោះវៀនផងដែរ។

- ជម្ងឺអស់កម្លាំងរ៉ាំរ៉ៃ (Chronic fatigue syndrome)៖ បង្កឡើងដោយភាពអស់កម្លាំងខ្លាំង ដែលមានរយៈពេលយ៉ាងហោចណាស់ ប្រាំមួយខែ ហើយដែលមិនអាចពន្យល់បាន ពេញលេញយោងទៅតាមស្ថានភាពសុខភាព។

| ប្រភេទកម្សោយ | និយមន័យ | លក្ខណៈវិនិច្ឆ័យ |
|---|---|---|
| **ពិបាកធ្វើចលនាលើ** | សំដៅទៅលើ ការចុះខ្សោយតាមរយៈការខូចខាត ឬការបាត់បង់ជាអចិន្ត្រៃយ៍នៃផ្នែក អវយវៈលើ (ដៃ) រួមទាំងភាពរួមស្វិត ភាពកន្ត្រាក់ នៃសាច់ដុំឬមិនកម្រើកបានដោយសារប្រព័ន្ធ សរសៃប្រសាទពាក់ព័ន្ធនឹងដៃ។ | ដាច់ដៃ (ផ្នែកនៃប្រអប់ដៃ ឧទាហរណ៍៖ ម្រាមដៃ សន្លាក់ដៃ ក្រោមកំភួនដៃ សន្លាក់កែងដៃ លើកែងដៃ សន្លាក់ស្មា និងហួសសន្លាក់ ស្មា) ស្វិតសាច់ដុំដៃ គាំងសន្លាក់ដៃ បាក់ឆ្អឹងដៃ ធ្ងន់ធ្ងរ សាច់ដុំដៃរួញខ្លី ខូចចលករខួរក្បាល ដៃខ្វេរ ដៃកែក ទន់ដៃ ខូចស្មា និងខូចទ្រង់ទ្រាយដៃ។ |
| **ពិបាកធ្វើចលនាក្រោម** | សំដៅទៅលើការចុះខ្សោយ ការខូចខាត ឬការបាត់បង់ជាអចិន្ត្រៃយ៍នៃអវយវៈក្រោម(ជើង) រួមទាំងភាពរួមស្វិត ភាពកន្ត្រាក់ នៃសាច់ដុំ ឬប្រព័ន្ធសរសៃប្រសាទពាក់ព័ន្ធនឹងជើង។ | ដាច់ជើង (ប្រអប់ជើង សន្លាក់កជើង ក្រោមជង្គង់ សន្លាក់ជង្គង់ លើជង្គង់ សន្លាក់ត្រគាក...) ស្វិតសាច់ ដុំជើង គាំងសន្លាក់ជើង បាក់ឆ្អឹងធ្ងន់ធ្ងរ សាច់ដុំរួញខ្លី ខូចចលករខួរក្បាល ជើងខ្វេរ ជើងកែក ទន់ជើង ភ្លាត់ត្រគៀកធ្ងន់ធ្ងរ ស្លាប់មួយ ចំហៀងខ្លួន ឬមួយកំណាត់ ខ្លួន ខូចសសៃធ្ងន់ធ្ងរ គ្រិចធ្ងន់ធ្ងរ រលាកធ្ងន់ធ្ងរ។ |
| **ពិបាកសម្របសម្រួលដងខ្លួន ខ្នងនិងសរីរាង្គ** | សំដៅលើការខូចទ្រង់ទ្រាយនៃដងខ្លួន ឬខ្នងនិងសរីរាង្គផ្សេងៗ | ខូចទ្រង់ទ្រាយឆ្អឹងខ្នង (កោង ទៅមុខ កោងទៅក្រោយ ឬកោងទៅចំហៀង) |

| | | |
|---|---|---|
| **ផ្សេងៗនៃរាងកាយ** | នៃរាងកាយដែលធ្វើឱ្យចុះខ្សោយ ឬបាត់បង់មុខងារនៃ សរីរាង្គនោះ ជាអចិន្ត្រៃយ៍។ | ឆ្អឹងកងក (កោង ឬវៀច) ពិការដោយសារ ផលវិបាកនៃជម្ងឺរបួសខួរឆ្អឹងខ្នង ជម្ងឺលើសសម្ពាធឈាម និងជម្ងឺស្រ្តូប...។ |
| **ពិការភាពសរីរាង្គខាងក្នុង** | សំដៅលើការរះកាត់នៃសរីរាង្គខាងក្នុងសំខាន់ៗ ដែលបានចុះខ្សោយ ខូចខាតសរីរាង្គខាងក្នុង ឬការចុះខ្សោយមុខងារនៃភាពស៊ាំនិងមានជម្ងឺរ៉ាំរ៉ៃ ជាអចិន្ត្រៃយ៍ (ពិការភាពនេះត្រូវមានការបញ្ជាក់ ពីគ្រូពេទ្យជំនាញ)។ | មានប្រវត្តិរះកាត់ធំ ឬកំពុងមានជម្ងឺរ៉ាំរ៉ៃឬខ្សោយខូចខាតទាំងស្រុងនៃ មុខងារសរីរាង្គ ខាងក្នុង (ឧទាហរណ៍៖ បេះដូង ក្រលៀន លំពែង ប្រព័ន្ធដង្ហើម តម្រងនោម ពោះវៀន ថ្លើម ក្រពះ ឬសរីរាង្គផ្សេងទៀត។ |

### ១.៤.២ ពិការភាពញាណដឹង

- **កម្សោយគំហើញ ឬពិបាកក្នុងការមើល៖** សំដៅដល់ "ការពិបាកក្នុងការមើល"។ "ពិការភាពភ្នែក" ច្រើនតែត្រូវបានគេពិពណ៌នាអំពីមនុស្សម្នាក់ដែលមានសមត្ថភាពមើលឃើញត្រឹម ១០% ឬតិចជាងនេះ វាមិនបង្ហាញថាបុគ្គលនោះ ពិការភាពភ្នែកទាំងស្រុងនោះទេ។ ហើយមានតែ ១០% នៃជនមានពិការភាពភ្នែកសរុបតែប៉ុណ្ណោះដែល មានពិការភាពភ្នែកទាំងស្រុង ហើយ ៩០% ទៀតត្រូវបានគេពិពណ៌នាថាជាការចុះខ្សោយនៃការមើលឃើញ។
- **កម្សោយការស្តាប់៖** សំដៅលើការពិបាកក្នុងការស្តាប់។ **"ថ្លង់"** ពិពណ៌នាអំពីបុគ្គលដែលមានការពិបាកក្នុងការស្តាប់ធ្ងន់ធ្ងរឬមិនអាចស្តាប់ឮទាល់តែសោះ។ អ្នកអាចទទួលរងការបាត់បង់ការស្តាប់នៅពេលឈានចូលវ័យជំទង់ ឬវ័យចំណាស់វាត្រូវ បានគេហៅជា ញឹកញាប់ថា "ថ្លង់" ។

| ប្រភេទកម្សោយ | និយមន័យ | លក្ខណៈវិនិច្ឆ័យ |
|---|---|---|
| **ពិបាកក្នុងការស្តាប់** | សំដៅលើ ការពិបាកឬ លទ្ធភាពនៃការស្តាប់ចុះ ខ្សោយ ខូចខាត ឬបាត់បង់ ការស្តាប់ទាំងស្រុង។ | ថ្លង់ ត្រចៀកអត់រន្ធពុំមានក្រដាសត្រចៀក ធ្លាយក្រដាសត្រចៀក ហៀរដំបៅអំបែកធូន់ធូរ រន្ធត្រចៀកមានដុំពក។ |
| **ពិបាកក្នុងការនិយាយ** | សំដៅលើការពិបាកក្នុងការបញ្ចេញសំឡេង និយាយ មិនច្បាស់ ឬនិយាយមិន រួចទាល់តែសោះឬ អ្នកដទៃពិបាកស្តាប់។ | ការនិយាយត្រឡាន់(អណ្តាតធំ) និយាយត្រដិតធូន់ធូរ ឆែប ក្រអូមមាត់ក្រឡើតមិនល្អ ក្ងរ និយាយមិនច្បាស់ និយាយមិន ចេញ ឬគ។ល។ |
| **ពិបាកក្នុងការមើល** | សំដៅលើ ការចុះខ្សោយ ខូចខាត ឬមិនអាចមើលឃើញ (ពីកំណើត ដោយសារគ្រោះថ្នាក់ ឬរបួស ឬជម្ងឺ ឬវ័យជរា...។ល។) | ងងឹតភ្នែកម្ខាងឬទាំងសងខាង ស្វិតសរសៃបាតភ្នែក ភ្នែកលៃនមើលមិនឃើញ កន្ទុយថ្លែន ធូន់ធូរបណ្តាលឱ្យមានប្រែងចាក់ ភ្នែកស្រលៀង ភ្នែកម្ងប ធ្លាក់ត្របកភ្នែក សម្លាកកញ្ចក់ភ្នែក សម្ពាធទឹកក្នុងភ្នែកកើនឡើង របោកសសៃបាតភ្នែក ងងឹតពណ៌។ |

### ១.៤.៣ ពិការភាពសតិបញ្ញា

វាជាជម្ងឺជាក់លាក់ និងជាប់លាប់មួយនៃប្រព័ន្ធសរសៃប្រសាទកណ្តាលរបស់មនុស្សដែលប៉ះពាល់ដល់សមត្ថភាពរបស់ពួកគេក្នុងការរៀនសូត្រដូចមនុស្សទូទៅ។ នេះអាចប៉ះពាល់ដល់សមត្ថភាពរបស់ពួកគេក្នុងការយល់ពីអ្វីដែលពួកគេបានឃើញនិងឮ ឬភ្ជាប់ ព័ត៌មានរវាងផ្នែកផ្សេងៗនៃខួរក្បាល។ មួយក្នុងចំណោមសូចនាករទូទៅនៃការចុះខ្សោយការរៀនសូត្រ គឺភាព

ខុសគ្នារវាងសក្ដានុពលរបស់បុគ្គលម្នាក់ៗ (សមត្ថភាពជាក់ស្ដែង និងបញ្ហា) និងកម្រិតនៃសមិទ្ធិផលសម្រេចបានរបស់ពួកគេ។

| ប្រភេទកម្សោយ | និយមន័យ | លក្ខណៈវិនិច្ឆ័យ |
|---|---|---|
| **ដោនស៊ីនដ្រូម** | សំដៅលើវិបល្លាសហ្សែន ជនមានបញ្ហានេះតែងមានភិន ភាគលក្ខណៈមុខមាត់សម្គាល់ ពិសេស មានបញ្ហាលូតលាស់ យឺតយ៉ាវ បញ្ហាក្នុងការមើល ការស្ដាប់និងសុខភាពផ្សេងៗទៀត។ | មិនចងចាំ ពិបាកខ្លាំងក្នុងការ រៀនសូត្រ មិនសូវយល់ដឹង។ មិនស្ដាប់បង្គាប់ ឆាប់ខឹងមួម៉ៅ បោកក្បាលពេលខឹង ការនិយាយស្ដីមិនច្បាស់ មិនអាចចាត់ចែងសកម្មភាពរស់នៅប្រចាំថ្ងៃដោយខ្លួនឯងបាន។ |
| **អូទីស្សឹម** | សំដៅលើបញ្ហាខួរក្បាល ដែលអភិវឌ្ឍមូលដ្ឋានខួរក្បាលយឺត ដោយមិនដឹងមូលហេតុ ឬវិធីព្យាបាលឱ្យជាសះស្បើយ។ អូទីស្សឹមអាចមានកម្រិត ស្រាលមធ្យម និងធ្ងន់។ | មិនដឹងពីអារម្មណ៍ឬការឆ្លើយតបរបស់អ្នកដទៃ។ ពិបាកនិយាយពីអារម្មណ៍របស់ខ្លួន ឬ ក្នុងការឆ្លើយតបទៅអ្នកស្ដាប់វិញ។ សកម្មភាពដដែលៗ និងពិបាកក្នុងការទទួលយក ឬ ពិបាកក្នុងការសម្របខ្លួនជាមួយបរិបទជុំវិញខ្លួន។ |
| **ពិការចលករខួរក្បាល** | សំដៅលើសរសៃប្រសាទមិនរីកចម្រើនដែលជះឥទ្ធិពលដល់ចលនារាងកាយ និងការសម្របសម្រួលសាច់ដុំបណ្ដាលមកពីការខូចខាតផ្នែកជាក់លាក់មួយ ឬច្រើននៃខួរក្បាល ហើយជាទូទៅកើតឡើងមុនពេលអំឡុងពេលឬភ្លាមៗបន្ទាប់ពីកំណើត។ | ដៃជើងរឹង ការធ្វើចលនាមិន ប្រក្រតី ញ័រ ឬចលនាដោយអចេតនា មិនអាចធ្វើចលនាបាន ស្ពឹកស្រពន់ ឬសាច់ដុំរឹងការហៀរទឹកមាត់និងមានភាពលូតលាស់យឺតខុស ធម្មតា រួមទាំងការនិយាយ និងអាកប្បកិរិយា។ |

### ១.៤.៤ ពិការភាពផ្លូវចិត្ត

វាមានសារៈសំខាន់ណាស់ក្នុងការដឹងថារាល់បញ្ហាសុខភាពផ្លូវចិត្តទាំងអស់ មិនមែនសុទ្ធតែជាកម្សោយនោះទេ។ វាត្រូវបានចាត់ទុកថាជាពិការភាពផ្លូវចិត្ត លុះត្រាតែវាមានផលប៉ះពាល់ដែលមានរយៈពេលវែងក្នុងសកម្មភាពប្រចាំថ្ងៃ។ ស្ថានភាពសុខភាពផ្លូវចិត្តមានច្រើនប្រភេទ ខ្លះអាចមើលឃើញ ខ្លះមិនអាចមើលឃើញនោះទេ។ ទោះជាយ៉ាងណាក៏ដោយអ្នកដែលមានបញ្ហាសុខភាពផ្លូវចិត្ត ឬប៉ះពាល់ផ្លូវចិត្ត ភាគច្រើនត្រូវទទួលបានការរើសអើង។

- ជម្ងឺវិកលចរិក៖ ជារឿយៗត្រូវបានគេចាត់ទុកថាជាស្ថានភាពសុខភាពផ្លូវចិត្ត ធ្ងន់ធ្ងរបំផុត។
- ជម្ងឺផ្លូវចិត្ត រួមមានការបាក់ទឹកចិត្ត ថប់បារម្ភ ជម្ងឺបាយប៉ូឡា (bipolar disorder)។
- ជម្ងឺភ្លេចភ្លាំង (Dementia)៖ ភាគច្រើនកើតមានចំពោះមនុស្សវ័យចំណាស់ ប៉ុន្តែជម្ងឺភ្លេចភ្លាំងនៅដំណាក់កាលដំបូងក៏អាចកើតមានចំពោះមនុស្សវ័យក្មេងផងដែរ។
- ជម្ងឺស្ត្រេស (Post Traumatic Stress Disorder)៖ ការប៉ាន់ប្រមាណបាន ឱ្យដឹងថា ២៨.៤% នៃប្រជាជនកម្ពុជាទទួលរងពីជម្ងឺស្ត្រេស សញ្ញាណទូទៅទាក់ទងនឹងជម្ងឺស្ត្រេសនេះ គឺពិបាកក្នុងការផ្តោតអារម្មណ៍ ឬចងចាំ។
- ភាពមិនប្រក្រតីនៃរបបអាហារ (Eating Disorders including Anorexia and Bulimia)៖ ទាក់ទងនឹងការតមអាហារ ការញ៉ាំមិនទៀងទាត់ ញ៉ាំលើសកម្រិត វាក៏ជាផ្នែកមួយពាក់ព័ន្ធនឹងសុខភាពផ្លូវចិត្តដែរ។
- ជម្ងឺភ័យខ្លាច (Obsessive-Compulsive disorders)៖ វាកើតនៅពេលដែលនរណាម្នាក់ទទួលរងនូវការបង្ខិតបង្ខំ ឬអ្វីដែលពួកគេមិនចង់បាន។

| ប្រភេទកម្សោយ | និយមន័យ | លក្ខណៈវិនិច្ឆ័យ |
|---|---|---|
| **ពិការភាពផ្លូវចិត្ត** | សំដៅលើវិបត្តិផ្នែក អាកប្បកិរិយា អារម្មណ៍ និងការគិត ដែលកើតឡើងជាប្រចាំ ហើយរំខានដល់ការ បំពេញមុខងារប្រចាំថ្ងៃ។ | ជំងឺមន្ទិលសង្ស័យ វិកលចរិក ខូចសតិអារម្មណ៍ តានតឹង ផ្លូវចិត្ត ជំងឺបាក់ទឹកចិត្ត ថប់អារម្មណ៍ ជំងឺវង្វេង អាក្រាត និយាយសើច យំ ច្រៀងរាំ លេងតែម្នាក់ឯងខុស |

| | | |
|---|---|---|
| | | ប្រក្រតី ស្ទឹងស្មាធ ដេរគេ ដេរឯង វាយ ឬប្រព្រឹត្តអំពើ ហឹង្សាដោយមិន ដឹងខ្លួន មិនដឹងគ្រោះថ្នាក់។ យំរាំតែម្នាក់ឯង ជូនកាលក៏ស្ងាត់ មិននិយាយស្តី ចូលចិត្ត ដាក់ទោសឬធ្វើបាបលើខ្លួនឯងដោយមិន ខ្វល់ ពីគ្រោះថ្នាក់។ |
| **ពិបាកក្នុងការចងចាំ** | សំដៅលើសមត្ថភាពយល់ដឹង ការវែកញែក ការសម្រេចចិត្តដោយ ប្រើប្រាស់ភាសា ការនិយាយ ការស្តាប់ និងការអានអក្ខរាវិរុទ្ធ ឬការគិតលេខ នពន្ធដែលបណ្តាលមកពីការចុះខ្សោយ សមត្ថភាពរ៉ាំរ៉ៃ។ ឬមុខងារខួរក្បាល ការអភិវឌ្ឍខួរក្បាលនិងជំងឺវង្វេងវង្វាន់។ | ភាពចាស់ជរា របួសខួរក្បាល តំណពូជ ការរួមតូចនៃសរសៃ ឈាមដែលផ្តល់ លំហូរឈាមទៅខួរក្បាលជំងឺសរសៃ ឈាមបេះដូង ដុំសាច់ក្នុងខួរក្បាល កង្វះអាហារូបត្ថម្ភ និងជំងឺវង្វេងវង្វាន់ បណ្តាលមកពីជំងឺ ឆ្លងរ៉ាំរ៉ៃ។ |

### ១.៤.៥ ពិការភាពផ្សេងៗ

| ប្រភេទកម្សោយ | និយមន័យ | លក្ខណៈវិនិច្ឆ័យ |
|---|---|---|
| **ជំងឺរមួលសារពាង្គកាយមិនប្រក្រតី** | សំដៅលើជំងឺប្រព័ន្ធប្រសាទខួរក្បាលរ៉ាំរ៉ៃដែលបង្កឱ្យមានការរំខាន ដល់ដំណើរការធម្មតារបស់ កោសិកាខួរក្បាលដែលប៉ះពាល់ ដល់សតិស្មារតី ចលនារាងកាយ ក្នុងរយៈពេលខ្លី។ | ប្រកាច់ឬកន្ត្រាក់សាច់ដុំ បែកពពុះមាត់ ភ្នែកស្លីឡើងលើ ខាំអណ្តាតហើយសន្លប់ បាត់ស្មារតីមួយសន្ទុះក្រោយមកក៏ដឹងខ្លួន ឡើងវិញហើយភ្លេចរឿងដែលកើតមាន ឡើង |
| **ពិការភាពផ្សេងៗ** | សំដៅលើការពិបាកបំពេញ មុខងារនៃរាងកាយសង្គម ឬមាន | មុខមាត់ខូចទ្រង់ទ្រាយ ក្បាលធំ តឿ ក្រិន ពកក ផលវិបាកក្នុងការបំពេញមុខងារ |

| | | |
|---|---|---|
| | ពិការភាពដែលមិនអាចចាត់ចូលជាប្រភេទពិការភាពណាមួយខាងលើឬមានពិការភាពច្រើនប្រភេទទៀត | ដោយសារគ្រោះថ្នាក់ (រលាកទឹកអាស៊ីត ទឹកក្តៅ ឬរលាកភ្លើង)។ |

**ពិការភាព "កំបាំង"**

ពិការភាពលាក់កំបាំង ឬមើលមិនឃើញ គឺជាស្ថានភាពផ្លូវកាយ ផ្លូវចិត្ត ឬសរសៃប្រសាទដែលមិនអាចមើលឃើញពីខាងក្រៅ ប៉ុន្តែអាចកំណត់ ឬប្រឈមនឹងចលនា អារម្មណ៍ ឬសកម្មភាពរបស់មនុស្ស។ ឧទាហរណ៍រួមមាន ការឈឺចាប់ខ្លាំង អស់កម្លាំង វិលមុខ ខូចមុខងារនៃការយល់ដឹង របួសខួរក្បាល ការលំបាកក្នុងការសិក្សា និងបញ្ហាសុខភាពផ្លូវចិត្ត ហើយក៏អាចសំដៅទៅលើការចុះខ្សោយនៃការស្តាប់ និងការមើលផងដែរ។

វាជារឿងសំខាន់ដែលត្រូវយល់ថាការចុះខ្សោយទាំងនេះ មិនតែងតែច្បាស់សម្រាប់អ្នកមើលនោះទេ ប៉ុន្តែជួនកាល ឬតែងតែអាចកំណត់សកម្មភាពប្រចាំថ្ងៃ និងមានចាប់ពីបញ្ហាប្រឈមកម្រិតស្រាលរហូតដល់កម្រិតធ្ងន់ធ្ងរ និងប្រែប្រួលពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត។

## ១.៥ ឧបសគ្គចំពោះបរិយាបន្នពិការភាព

វិធីល្អបំផុតមួយដើម្បីស្វែងយល់ពីគំរូសង្គមនៃពិការភាព និងវិធីដើម្បីយកឈ្នះការមិនដាក់បញ្ចូលជនដែលមានពិការភាពគឺនៅលើ**"ការរារាំងឧបសគ្គ"**។ មានទិដ្ឋភាពនៃសង្គមជាច្រើនដែលធ្វើឱ្យជីវិតមានការលំបាកសម្រាប់បុគ្គលដែលមានកម្សោយ ហើយមិនដាក់បញ្ចូលពួកគេក្នុងការចូលរួមក្នុងសង្គមពេញលេញ។ រនាំងឧបសគ្គសំខាន់ៗរួមមាន៖

**ឧបសគ្គបែបអាកប្បកិរិយា៖** មានឥរិយាបថសង្គម និងវប្បធម៌ និងការសន្មតជាច្រើនទាក់ទងនឹងមនុស្សមានកម្សោយរួមមាន ការវិនិច្ឆ័យមិនត្រឹមត្រូវ ការប្រកាន់ពូជសាសន៍ ការរើសអើង និងការមិនដាក់បញ្ចូលទៅក្នុងសង្គម។ ឧទាហរណ៍ ការសន្មតថាបុគ្គលដែលមានពិការភាពមិនអាចធ្វើការបាន មិនមានឯករាជ្យភាព មិនអាចរួមភេទ មិនគួរមានកូន ត្រូវការការ

គាំពារដូចជាកូនក្មេង ងាយប្រឈមនឹងគ្រោះថ្នាក់ និងជនមានពិការភាពមិនគួរឱ្យឃើញ ព្រោះធ្វើឱ្យអ្នកដទៃមានអារម្មណ៍មិនល្អ។

**ឧបសគ្គបែបបរិស្ថាន ឬ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តៈ** ទាំងនេះជារនាំងដែលត្រូវបានផ្សាភ្ជាប់ទៅនឹងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបរិស្ថានជុំវិញ គ្របដណ្តប់លើឧបសគ្គធំៗដែលរារាំងការចូលរួមដែលមានភាពស្មើគ្នា មានដូចជាៈ កាំជណ្តើរ ច្រកទ្វារចេញចូលតូចចង្អៀត តុខុសស្តង់ដារ គ្មានជម្រាលផ្លូវ បង្គន់អនាម័យមិនបង្កលក្ខណៈងាយស្រួល លំនៅដ្ឋានដែលមិនមានភាពងាយស្រួល កន្លែងអង្គុយមិនមានភាពល្អប្រសើរ មិនមានពន្លឺគ្រប់គ្រាន់ ជណ្តើរយន្តខូច កំរាលថ្មផ្លូវក្រាលមិនស្មើគ្នាទាំងក្នុងនិងនៅលើផ្លូវសាធារណៈ។

**ឧបសគ្គបែបព័ត៌មានឬការទំនាក់ទំនងៈ** ឧបសគ្គទាំងនេះត្រូវបានផ្សាភ្ជាប់ទៅនឹងកង្វះភាសាសញ្ញា ឬអ្នកបកប្រែសម្រាប់មនុស្សដែលមានបញ្ហាខ្សោយសោតវិញ្ញាណ (ការស្តាប់)។ កង្វះនូវការផ្តល់ពត៌មានក្នុងទម្រង់ផ្សេងៗគ្នាដូចជា សំភារៈបោះពុម្ពដែលបង្កលក្ខណៈងាយស្រួល (ពុម្ពអក្សរធំ ការរចនាក្រហ្វិកសាមញ្ញ)។

**ឧបសគ្គបែបស្ថាប័នៈ** ឧបសគ្គទាំងនេះពាក់ព័ន្ធនឹងការរើសអើង ក៏ដូចជាច្បាប់ការងារ ប្រព័ន្ធបោះឆ្នោត និងគោលនយោបាយសិក្សាអប់រំនៅមានកម្រិត។

- ❖ មនុស្សមួយចំនួនមានកម្សោយជាក់លាក់ ប៉ុន្តែជារឿយៗបរិយាកាសជុំវិញ និងអាកប្បកិរិយារបស់សង្គមទេដែលបានរារាំងពួកគេមិនឱ្យចូលរួមបាន។
- ❖ វាជារឿងសំខាន់ដែលត្រូវដឹងថាពិការភាពមិនមែនជា បុគ្គលិកលក្ខណៈនោះទេ វាជាលទ្ធផលនៃការឆ្លើយតប (អន្តរកម្ម) របស់បុគ្គល និងបរិយាកាសរបស់គាត់។
- ❖ ស្ថានភាពដែលរារាំង គឺនៅពេលដែលមនុស្សម្នាក់មិនមានកាយសម្បទាគ្រប់គ្រាន់ និងមិនមានឱកាសដូចអ្នកដទៃ។

# ជំពូកទី ២៖ ការងារ និងជនមានពិការភាព

## តើ "បរិយាបន្ន" មានន័យដូចម្តេច?

យោងតាម វចនានុក្រមដែលចំណាស់ជាងគេនៅសហរដ្ឋអាមេរិក (មីរីម-វេបស្ទ័រ) ពាក្យថា "បរិយាបន្ន" គឺការពិពណ៌នាអំពីអ្វីមួយដែលមានលក្ខណៈទូលំទូលាយទៅលើការផ្តោត ឬវិសាលភាព ដោយវាត្រូវ បានរួមបញ្ចូលគ្រប់របស់របរ ការចំណាយ ឬសេវាកម្ម។ ហើយវាក៏ត្រូវបានគេប្រើ ដើម្បីពណ៌នាអំពី អ្វីមួយដែលត្រូវបានស្វាគមន៍ចំពោះមនុស្សគ្រប់គ្នា ជាពិសេសអ្នកដែលងាយរងគ្រោះ ជាប្រវត្តិសាស្ត្រ ដោយសារកត្តាដូចជាពូជសាសន៍ យេនឌ័រ ភេទ ឬសមត្ថភាពជាដើម (មីរីម-វេបស្ទ័រ, ២០២៣)។

នៅក្នុងបរិបទនៃគោលការណ៍ណែនាំនេះ

យើងកំពុងកំណត់យ៉ាងជាក់លាក់នូវពាក្យសម្រាប់ជនមានពិការភាព ដូច្នេះ"បរិយាបន្ន" វាត្រូវ បានចាប់ផ្តើមឡើងពីយើងទាំងអស់គ្នាក្នុងការគិតគូរដល់មនុស្សគ្រប់រូបដែលមានប្រភេទនៃ ការចុះខ្សោយផ្សេងៗគ្នា (ដូចដែលបានកំណត់ក្នុងជំពូកទី១) ដើម្បីធានា ថាពួកគេត្រូវបាន ដាក់បញ្ចូលក៏ដូចជាទទួលបានឱកាសស្មើភាពគ្នាដូចមនុស្សគ្រប់រូបដទៃទៀតដែរ។

## "បរិយាបន្នការងារ" សម្រាប់ជនមានពិការភាព

បរិយាបន្នការងារសំដៅទៅលើបរិយាកាសការងារដែលនិយោជិតត្រូវបានសម្របសម្រួលដោយមិនលំអៀងនិងស្មើភាពដោយមិនគិតអំពី ពូជសាសន៍ សាសនា សមត្ថភាព យេនឌ័រ ជំនឿរបស់ពួកគេជាដើម ដែលបង្កើតនិងពង្រីកឱ្យមានឱកាសសម្រាប់អ្នកដែលស្ថិតនៅក្នុងក្រុមងាយរងគ្រោះ។ នេះគឺជាកន្លែងដែលបរិយាបន្នការងារពិតប្រាកដត្រូវបានកំណត់យ៉ាងច្បាស់ជាមួយនឹងសកម្មភាព និងវិធានការចាំបាច់ដើម្បីសម្រេចបាននូវសមិទ្ធិផលដោយមិនមែនបានតែនិយាយនោះទេ គឺត្រូវបង្កប់ទង្វើក្នុងនោះផងដែរ។ បរិយាបន្នការងារសម្រាប់ជនមានពិការភាពគឺមិនមានករណីលើកលែងនោះទេ នេះមានន័យថាពេលដែលស្ថាប័នមួយទទួលយកជនមានពិការភាពមកបម្រើការងារដែលស័ក្តិសមនឹងសមត្ថភាពរបស់ពួកគេជាមួយនឹងប្រាក់កម្រៃសមស្រប ក៏ដូចជាបរិយាកាសការងារដែលបង្កលក្ខណៈងាយស្រួលដោយផ្តល់ជាការគាំទ្រដើម្បីជួយឲ្យពួកគេបម្រើការងារប្រកបដោយផាសុកភាពបរិយាកាសដែលមានការសម្របសម្រួលនិងការគោរពគ្នាទៅវិញទៅមក។ ឧទាហរណ៍នៃបរិយាបន្នការងារសម្រាប់ជនមានពិការភាពអាចរកបាននៅក្រុមហ៊ុន ម៉ៃក្រូសូហ្វ។ ដោយក្រុមហ៊ុន ម៉ៃក្រូសូហ្វនេះផងដែរ មានកម្មវិធីមួយដែលមានគោលបំណងយកជនដែលមានជំងឺអូទីស្សឹម (ASD) មកបម្រើការងារក្នុងស្ថាប័នរបស់ពួកគេ។ កម្មវិធីនេះផ្តល់ឱ្យបេក្ខជនដែលមានជំងឺអូទីស្សឹមនូវឱកាសដើម្បីបង្ហាញពីភាពខ្លាំងរបស់ពួកគេនៅក្នុងផ្នែកដូចជាការយកចិត្តទុកដាក់ទៅលើព័ត៌មានលម្អិត ការកត់ចំណាំគម្រូភាព និងការគិតបែបវិភាគ។ កម្មវិធីនេះក៏ផ្តល់នូវការសម្របសម្រួលសមរម្យ ការគាំទ្រ និងការណែនាំ ដើម្បីជួយឱ្យបុគ្គលិកទទួលបានជោគជ័យក្នុងតួនាទីរបស់ពួកគេ។ ក្រុមហ៊ុនម៉ៃក្រូសូហ្វ ក៏បានធ្វើឱ្យផលិតផលរបស់ខ្លួនកាន់តែបង្កលក្ខណៈងាយស្រួល (ផាសុកវត្ថុ) ជាងមុនទៅទៀតក្នុងការគាំទ្រដល់បុគ្គលិកដែលមានពិការភាព។

# ២.១ ហេតុអ្វីបរិយាកាសការងារសំខាន់

**បរិយាបន្នការងារ** សំដៅលើបុគ្គលមានពិការភាពធ្វើការជាមួយមិត្តរបស់ពួកគេដែលមិនមានពិការភាព នៅក្នុងទីផ្សារការងារដែលមានការប្រកួតប្រជែង (ជាមួយនឹងការទទួលបានអត្ថប្រយោជន៍ដូចគ្នានិងឱកាសការងារស្មើគ្នា) ដូច្នេះហើយវាធានាថាគ្មានបុគ្គលណាម្នាក់ត្រូវបានដកចេញពីឱកាសការងារប្រកបដោយគុណភាពដោយសារពិការភាពរបស់ពួកគេនោះទេ ។ បរិយាបន្នការងារ គឺធានាថាជនមានពិការភាពមានសិទ្ធិទទួលបានការងារ ការសម្របសម្រួលសមរម្យ និងអត្ថប្រយោជន៍ស្មើៗគ្នាដូចជាមិត្តភក្តិដែលមិនមានពិការភាពរបស់ពួកគេ ជាមួយនឹងឧបករណ៍ដែលពួកគេត្រូវការដើម្បីសម្រេចបាននូវគោលដៅ (កម្មវិធីអាហាររូបករណ៍វិជ្ជាជីវៈ, អិន.ឌី.) ។

## ហេតុអ្វីយើងគួរបង្កើតបរិយាបន្នការងារសម្រាប់ជនមានពិការភាព?

ដំបូង រឿងដែលសំខាន់បំផុតគឺការបង្កលក្ខណៈងាយស្រួល (ជាសុករវត្ថុ) ជាបញ្ហាសិទ្ធិមនុស្ស ដែលមានន័យថា ជនមានពិការភាពគឺទទួលបានសិទ្ធិចូលរួមដោយស្មើភាពគ្នានៅក្នុងសង្គមរួមទាំងនៅកន្លែងធ្វើការផងដែរ។ ចំណុចនេះត្រូវបានលើកឡើងនិងបង្ហាញក្នុងអំឡុងពេលផ្តល់សក្ខីកម្មនៅ ចំពោះមុខគណៈកម្មាធិការព្រឹទ្ធសភាសហរដ្ឋអាមេរិកស្តីពីសុខភាពការអប់រំ ការងារ និងប្រាក់សោធន នៅថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ ២០២២ ដោយប្រធានផ្នែកជាសុករវត្ថុរបស់ក្រុមហ៊ុនម៉ៃក្រូសូហ្វ ចេនី ឡាយ-ផ្លូវី (Microsoft Corporate Blogs, ២០២២)។ នៅពេលដែលបញ្ហាមួយត្រូវបានចាត់ទុកថាជាបញ្ហា សិទ្ធិមនុស្ស ហើយការមិនបានបំពេញ ឬការមិនឆ្ពោះទៅរកការសម្រេចបាននូវគោលដៅ វាអាចត្រូវបានពិពណ៌នាថាជាទម្រង់នៃការ ប្រឆាំងរើសអើងនឹងជនមានពិការភាព។

លើសពីនេះ គួបញ្ជាក់ផងដែរថា យោងតាមមាត្រា ទី២៧ នៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិស្តីពី "ការបម្រើការងារ និងការងារ" នៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ (CRPD) នៃអង្គការសហប្រជាជាតិដែលបានអនុម័តតាំងពីឆ្នាំ២០០៦ ហើយត្រូវបានផ្តល់សច្ចាប័នដោយប្រទេសចំនួន ១៨៦ នៅទូទាំងពិភពលោក ថាបុគ្គលដែលមានពិការភាពមានសិទ្ធិដូចគ្នាសម្រាប់ឱកាសការងារដូចមនុស្សដទៃទៀតដែរ។ ហើយទាំងអស់នេះដែរត្រូវបានរាប់បញ្ចូលទាំងសិទ្ធិក្នុងការជ្រើសរើសមុខរបរផ្ទាល់ខ្លួនដើម្បីទទួលបានប្រាក់កម្រៃសមធម៌សម្រាប់ការងារដែលអាចប្រៀបធៀបបាននិងការការពារពីការរើសអើងក្នុងបរិយាកាសការងារ (នាយកដ្ឋានសេដ្ឋកិច្ចនិងសង្គមកិច្ចនៃពិការភាពរបស់អង្គការសហប្រជាជាតិ ឆ្នាំ ២០០៨)។ ស្រដៀងគ្នានេះដែរ ក្នុងបរិបទក្នុងស្រុក នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ សម្តេចតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រីនៃកម្ពុជា បានមានប្រសាសន៍នៅក្នុងសេចក្តីថ្លែងការណ៍របស់លោក ស្តីពីផែនការ យុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ ២០១៩ - ២០១៨ ថា“ជនមានពិការភាព និងកុមារមានពិការភាព ដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការជំនះឧបសគ្គដោយខ្លួនឯងគឺត្រូវដាក់បញ្ចូលពួកគេទៅគ្រប់វិស័យដោយផ្អែកលើគោលការណ៍នៃសិទ្ធិស្មើគ្នា នឹងធ្វើឱ្យគុណភាពជីវិត និងជីវិតគ្រួសាររបស់ពួកគេ កាន់តែប្រសើរឡើង។ ក្នុងនាមជាប្រទេសមួយដែលអភិវឌ្ឍសុខុមាលភាពរបស់ជនមានពិការភាពគឺយើងត្រូវតែមានការពង្រឹង ក៏ដូចជាធ្វើឲ្យប្រសើរឡើងបន្តទៀត។

ថ្វីត្បិតតែវាជាបញ្ហាសិទ្ធិមនុស្សក៏ពិតមែន តែវាពិតជាពិបាកនឹងមើលឃើញថាតើអ្នកណាដែលជាអ្នកទទួលខុសត្រូវនិងចាប់ផ្តើមសកម្មភាពដើម្បីធានាឱ្យមានបរិយាបន្នការងារសម្រាប់ជនមានពិការភាព។ វាត្រូវបានលើកឡើងផងដែរ នៅក្នុងសក្ខីកម្មរបស់នាយកក្រុមហ៊ុន Microsoft ក៏ដូចជានៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិដែលវាចាំបាច់សម្រាប់រដ្ឋាភិបាលនានាក្នុង

ការអនុវត្តវិធានការដែលអាចឱ្យបុគ្គលមានពិការភាពទទួលបានឱកាសការងារ។ វិធានការបែបនេះពាក់ព័ន្ធនឹងការផ្តល់ការណែនាំនិងការគាំទ្រ ក៏ដូចជាការធានាថាកន្លែងធ្វើការជាកន្លែងដែលផ្តល់នូវការបង្ក លក្ខណៈងាយស្រួយ (ផាសុកវត្ថុ)។

## បរិយាបន្នការងារ - នៅក្នុងទិដ្ឋភាពរបស់វិទ្យាស្ថានឯកជន

និន្នាការអ្នកប្រើប្រាស់បានវិវឌ្ឍយ៉ាងឆាប់រហ័ស ជាពិសេសចាប់តាំងពីការចូលមកដល់នៃការប្រើប្រាស់អ៊ីនធឺណេតកាន់តែធ្វើឱ្យទូលំទូលាយ។ ជាមួយនឹងប្រភពព័ត៌មានដ៏ច្រើនលើសលប់បានធ្វើឱ្យពួកគេទទួលបានការអប់រំជាច្រើនដែលមិនធ្លាប់មានពីមុនមក ហើយនេះបានផ្តល់ឱ្យពួកគេនូវការបង្កើនថាមពលក្នុងការដឹងអំពីវិធីសាស្ត្រក្នុងការប្រើប្រាស់ទម្លាប់ក៏ដូចជាឥទ្ធិពលក្នុងការប្រើប្រាស់វា

ចំពោះមជ្ឈដ្ឋានជុំវិញរបស់ពួកគេជាមួយនឹងអ្វីដែលពួកគេយកចិត្ត ទុកដាក់ ហើយនោះគឺជាពេលដែលពួកគេបានចាប់ផ្តើមក្នុងការទទួលខុសត្រូវចំពោះ សាជីវកម្ម។ អ្នកប្រើប្រាស់កំពុងចាប់ផ្តើមស្វែងរកនូវសេវាកម្ម និងផលិតផលដែលតម្លៃ ការជឿទុកចិត្ត និងការអនុវត្តរបស់ក្រុមហ៊ុន ដោយស្របទៅនឹងពួកគេដែលជាអ្នកប្រើប្រាស់។ ដូច្នេះហើយ វាជាការងាយស្រួលក្នុងការសង្កេតឃើញថាក្រុមហ៊ុន ដែលខិតខំប្រឹងប្រែងក្នុងការសម្រេចបាននូវបរិយាបន្ននិងភាពចម្រុះ

នឹងអាចរក្សាបាននូវល្បឿនរបស់ពួកគេជាមួយនឹង

ទិដ្ឋភាពអាជីវកម្មដែលតែងតែផ្លាស់ប្តូរជានិច្ចកាល ខណៈពេលដែលក្រុមហ៊ុនទំនងជាមិនទទួលបានអត្ថប្រយោជន៍សូម្បីតែបន្តិចពីអ្នកប្រើប្រាស់នៅក្នុងជំនាន់នេះ។ ការកោតសរសើរនឹងត្រូវបានផ្តល់ទៅកាន់អ្នកដែលបង្កើតឱ្យមានបរិយាបន្ន។អ្នកប្រើប្រាស់បច្ចុប្បន្នលែងចង់បានផលិតផលតែមួយមុខទៀតហើយ ប៉ុន្តែពួកគេទាមទារនូវភាពចម្រុះនិងបរិយាបន្នដែលរួម

បញ្ចូលនៅក្នុងវប្បធម៌ និងការអនុវត្តរបស់ក្រុមហ៊ុន។ នេះគ្រាន់តែជាហេតុផលមួយដែលដកស្រកចេញពីទិដ្ឋភាពអ្នកប្រើប្រាស់វិជ្ជមាន អំពីមូលហេតុដែលវិទ្យាស្ថានឯកជនគួរតែបង្កើតឱ្យមានបរិយាបន្នការងារសម្រាប់ជនមានពិការភាព។ សម្រាប់ទិដ្ឋភាពមួយជ្រុងទៀតជាទូទៅវាគួរតែត្រូវបានគេដឹងថា វាជាសិទ្ធិរបស់ជនមានពិការភាពក្នុងការទទួលបានការងារ និងការសម្របសម្រួលសមរម្យ។

## ២.២. ក្របខ័ណ្ឌច្បាប់សម្រាប់ការងារពិការភាព

ប្រព័ន្ធច្បាប់សម្រាប់ការងារនៃពិការភាពបង្កើតឡើង ក្នុងគោលបំណងការពារសិទ្ធិជនមានពិការភាព និងធានាថាពួកគេមានឱកាសស្មើគ្នានៅកន្លែងធ្វើការ។ ប្រព័ន្ធនេះរួមបញ្ចូលនូវច្បាប់និងបទប្បញ្ញត្តិជាច្រើន ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ នៅក្នុងជំពូកនេះ យើងនឹងពិនិត្យមើលបទប្បញ្ញត្តិសំខាន់ៗមួយចំនួននៃច្បាប់ទាំងនេះ និងរបៀបដែលពួកគេអាចជួយនិយោជកក្នុងការបង្កើត ឱ្យមានបរិយាបន្នការងារនៅកន្លែងធ្វើការ។

មុននឹងណែនាំច្បាប់និងបទប្បញ្ញត្តិទាក់ទងនឹងបរិយាបន្នការងារ វាក្យស័ព្ទមួយចំនួនដែលតំណាងឱ្យភាគីពាក់ព័ន្ធពាក់ព័ន្ធកម្មវិធីរដ្ឋាភិបាល និងនិយមន័យរបស់ពួកគេដែលមានចែងក្នុងច្បាប់គួរតែត្រូវ បានដាក់ចេញ។

**ក្រុមប្រឹក្សាសកម្មភាពជនពិការ** គឺជាជាយន្តការសម្របសម្រួលថ្នាក់ជាតិ និងពិគ្រោះយោបល់លើបញ្ហាពិការភាពដែលត្រូវបានបង្កើតឡើងដោយព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ក្នុងច្បាប់ស្តីពី កិច្ចការពារ និងលើកកម្ពស់សិទ្ធិ

ជនពិការ។ ក្រុមប្រឹក្សាសកម្មភាពជនពិការ មានតួនាទីនិងទំនួលខុសត្រូវក្នុងការផ្តល់ការពិគ្រោះជាមួយអ្នកជំនាញលើបញ្ហា និងការស្តារនីតិសម្បទាជនមានពិការភាព ជំនួយដល់ក្រសួងស្ថាប័ននិងអង្គការពាក់ព័ន្ធក្នុងការរៀបចំគោលនយោបាយ។ ផ្តល់ការពិគ្រោះជាមួយអ្នកជំនាញលើបញ្ហាពិការភាព និងការស្តារនីតិសម្បទារបស់ក្រសួងស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាលសម្រាប់បង្កើតគោលនយោបាយផែនការយុទ្ធសាស្ត្រជាតិទាក់ទងនឹងជនមានពិការភាព និងការស្តារនីតិសម្បទា ជំរុញការអនុវត្តគោលនយោបាយច្បាប់ និងបទប្បញ្ញត្តិ ផ្សេងៗទាក់ទងនឹងបញ្ហាពិការភាព ការត្រួតពិនិត្យ ការវាយតម្លៃលើការអនុវត្តផែនការជាតិ សំណើរវិសោធនកម្មគោលនយោបាយ ច្បាប់ និងក្របខ័ណ្ឌច្បាប់។

**មូលនិធិជនពិការ (PWDF)**

មូលនិធិជនពិការ ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០១០ ស្របតាមច្បាប់ស្តីពីការការពារ និងលើកកម្ពស់សិទ្ធិជនពិការ។ មូលនិធិជនពិការគឺជាស្ថាប័នសាធារណៈដែលធានាសិទ្ធិជនមានពិការភាពក្នុងការទទួលបានសេវាស្តារនីតិសម្បទា និងការចូលរួមយ៉ាងពេញលេញនៅក្នុងសង្គម ដែលមានភារកិច្ចសំខាន់ៗដូចជា៖ ការផ្តល់សេវាស្តារនីតិសម្បទាដល់ ជនមានពិការភាព ការគ្រប់គ្រងមជ្ឈមណ្ឌលស្តារនីតិសម្បទា ការផ្តល់ជនមានពិការភាពជាមួយនឹងឱកាសក្នុងលើកកម្ពស់ និងបង្កើនសុខុមាលភាពរបស់ជនមានពិការភាព ការធ្វើសមាហរណកម្មជន មានពិការភាពទៅក្នុងសហគមន៍ រក្សាទុកដាក់ថវិកាដែលទទួលបានពីរដ្ឋាភិបាលនិងប្រភពផ្សេងៗ ប្រមូលប្រាក់ពិន័យពីប្រធានស្ថាប័ន និងនីតិបុគ្គលដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការការពារ

និងការលើកកម្ពស់សិទ្ធិជនពិការ ការផ្តល់មូលនិធិសម្រាប់ការអនុវត្តកម្មវិធីផ្សេងទៀតដែលគាំទ្រដល់ជនមានពិការភាព។ គាំទ្រស្ថាប័នដែលផ្តល់សេវាដល់ជនមានពិការភាព បង្កើតគោលនយោបាយជាតិ ការផ្គត់ផ្គង់ និងការគាំទ្រដល់ជនមានពិការភាព រៀបចំប្រអប់សប្បុរសធម៌សម្រាប់ជនមានពិការភាព គ្រប់គ្រងមូលនិធិវិនិយោគរបស់មូលនិធិជនពិការ។ ស្រាវជ្រាវនិងបណ្តុះបណ្តាលធនធានមនុស្សដល់ការផ្តល់សេវាស្តារនីតិសម្បទាដល់ជនមានពិការភាព ។

## ច្បាប់ជាតិស្តីពីបរិយាបន្នការងារសម្រាប់ជនមានពិការភាព

**ការងារអាទិភាពទី៣៖ ការលើកកម្ពស់សុខុមាលភាពជនមានពិការភាព**

បន្ទាប់ពីមានការដាក់ចេញអនុក្រឹត្យស្តីពីការជ្រើសរើសជនមានពិការភាពទៅបម្រើការងារក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានជំរុញឱ្យក្រសួងនិងស្ថាប័ននានាគួរតែមានជនមានពិការភាពបម្រើការងារយ៉ាងហោចណាស់ ២% ។

**ចង្កោមសកម្មភាព ១.៣.១៖**

- ការកែលម្អសុខុមាលភាព និងការលើកកម្ពស់សិទ្ធិរបស់ជនមានពិការភាព
- បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យពិការភាព
- ការអនុវត្តកម្មវិធីផ្ទេរប្រាក់សម្រាប់ជនពិការក្នុងសហគមន៍

- ផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការបង្កើតការងារសម្រាប់ជនមានពិការភាព
- សម្របសម្រួល ត្រួតពិនិត្យ និងលើកទឹកចិត្តដល់ក្រសួង ស្ថាប័ននិងសហគ្រាសឯកជន ក្នុងការផ្តល់ការងារដល់ជនមានពិការភាព។
- ការសម្របសម្រួលនិងលើកទឹកចិត្តដល់ក្រសួង ស្ថាប័ន និងសហគ្រាសឯកជន ដើម្បីរៀបចំលទ្ធភាពបរិយាបន្នសម្រាប់ជនមានពិការភាព។
- ការលើកទឹកចិត្តដល់ការស្តារនីតិសម្បទា និងភាសាសញ្ញា
- កិច្ចសហប្រតិបត្តិការជាមួយដៃគូរបស់អង្គការក្រៅរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍ និងបណ្តុះ- បណ្តាលអក្សរស្ទាប និងភាសាសញ្ញា។

**ជំពូកទី៧៖ ការងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ**

**មាត្រា ៣៣._**

ជនពិការដែលមានលក្ខណសម្បត្តិនិងសមត្ថភាពបំពេញនូវមុខងារតួនាទី និងការទទួលខុសត្រូវក្នុងមុខតំណែង មានសិទ្ធិចូលបម្រើការងារដោយគ្មានការរើសអើងរាប់ទាំង ការបម្រើការងារជាមន្ត្រី រាជការ កម្មករ និយោជិត កូនជាង ឬ កម្មសិក្សាការី ។

**មាត្រា ៣៤._**

នីតិបុគ្គលដែលជ្រើសរើសកម្មករនិយោជិតធ្វើការ ត្រូវទទួលយកជនពិការដូចមានចែងក្នុងមាត្រា ៣៣ នៃច្បាប់នេះ ឱ្យចូលធ្វើការតាមអត្រាកំណត់សមស្រប។ អត្រានេះ

ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីទទួលបន្ទុកវិស័យការងារ និងក្រុមប្រឹក្សា អភិវឌ្ឍន៍កម្ពុជា ។

**មាត្រា ៣៦._**

នីតិបុគ្គលដែលទទួលជនពិការឱ្យចូលធ្វើការតាមអត្រាកំណត់សមស្រប ត្រូវធ្វើសេចក្ដីជូនដំណឹងជាទៀតទាត់អំពីចំនួនកម្មករនិយោជិតធ្វើការទាំងអស់ និងកម្មករនយោជិតជាជនមានពិការភាពនៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច និងក្រសួងទទួលបន្ទុកវិស័យការងារ ។

**មាត្រា ៣៧._**

នីតិបុគ្គលដែលមិនអាចបំពេញតាមកាតព្វកិច្ច ដូចមានចែងក្នុងមាត្រា ៣៤ និងមាត្រា ៣៥ នៃច្បាប់នេះ ត្រូវបង់ភាគទានចូលហិបមូលនិធិនៃជនពិការ។

អត្រានៃការបង់ភាគទាន ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

**មាត្រា ៣៨._**

នីតិបុគ្គលត្រូវរៀបចំឱ្យ មានការសម្របសម្រួលសមស្របសម្រាប់ជនមានពិការភាពដែលជាបេក្ខជនដាក់ពាក្យសុំបម្រើការងារជាកម្មករនិយោជិត ឬកូនជាង ឬកម្មសិក្សាការីលើកលែងតែ ក្នុងករណីការសម្របសម្រួលនោះ មានបន្ទុកធ្ងន់ធ្ងរហួសហេតុ។

**មាត្រា ៤០._**

គ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈរបស់រដ្ឋ ឯកជន ឬអង្គការនានាត្រូវរៀបចំការសម្របសម្រួលសមស្របដល់ជនពិការដែលជាបេក្ខជនដាក់ពាក្យសុំ ចូលសិក្សា

ឬជាសិក្ខាកាម ឬជាកម្មសិក្សាការី លើកលែងតែក្នុងករណីការសម្របសម្រួលនោះ មានបន្ទុកធ្ងន់ធ្ងរហួសហេតុ ។

**ជំពូកទី៨៖ ការលើកទឹកចិត្ត**

**មាត្រា ៤៣._**

រដ្ឋត្រូវលើកទឹកចិត្តផ្នែកពន្ធដារនិងលើកទឹកចិត្តផ្សេងៗទៀត ស្របតាមច្បាប់ជាធរមានដល់និយោជក គ្រឹះស្ថានសិក្សា គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដែលបានទទួលជនពិការ ឱ្យចូលធ្វើការអប់រំបណ្តុះបណ្តាល ទៅតាមអត្រាកំណត់សមស្រប ឬលើសអត្រាកំណត់សមស្រប ដែលមានចែងក្នុងជំពូកទី ៧ នៃច្បាប់នេះ ។

**ជំពូកទី ១២៖ ទោសប្បញ្ញត្តិ**

**មាត្រា ៥៤._**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ចំពោះនីតិបុគ្គលដែលមិនព្រមបង់ចូលហិបមូលនិធិជនពិការ ដូចមានកំណត់នៅក្នុង មាត្រា ៣៧ នៃច្បាប់នេះ ដោយគ្មានមូលហេតុសមស្រប។

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ចំពោះប្រធានស្ថាប័នរដ្ឋដែលមិនព្រមអនុវត្តមាត្រា៣៥នៃច្បាប់នេះ ដោយគ្មានមូល ហេតុសមស្រប។ ការពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យសង្គម កិច្ច ។

**ជំពូកទី ១៣៖ អន្តរប្បញ្ញត្តិ**

**មាត្រា ៥៧._**

ទីកន្លែងសាធារណៈទាំងឡាយណាដែលបានសាងសង់មុនច្បាប់នេះចូលជាធរមាន ហើយមានលទ្ធភាព ត្រូវរៀបចំកែសម្រួលទីកន្លែងសាធារណៈនោះយ៉ាងយូររយៈពេល៥ (ប្រាំ) ឆ្នាំ ដើម្បីឱ្យជនមានពិការភាពមានលក្ខណៈងាយស្រួលចេញ-ចូលបាន។

ក្នុងករណីមិន គោរពតាមវាក្យខ័ណ្ឌខាងលើ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

**មាត្រា ៥៨._**

ទីកន្លែងសាធារណៈទាំងឡាយណាដែលបានសាងសង់មុនច្បាប់នេះចូលធរមាន ហើយមិនទាន់បានរៀបចំ ដូចមានចែងក្នុងមាត្រា ២៦ នៃច្បាប់នេះ ហើយដែលមានលទ្ធភាព ត្រូវរៀបចំកែសម្រួលទី កន្លែងសាធារណៈនោះ យ៉ាងយូររយៈពេល ៥ (ប្រាំ) ឆ្នាំ ។

ក្នុងករណីមិនគោរពតាមវាក្យខ័ណ្ឌខាងលើ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

**មាត្រា ៥៩._**

ក្រសួងស្ថាប័នរដ្ឋ និងនីតិបុគ្គលដែលជ្រើសរើសបុគ្គលិកចូលបម្រើការងារ ដូចមានចែងក្នុងមាត្រា ៣៤ និងមាត្រា ៣៥ នៃច្បាប់នេះ ត្រូវចាប់អនុវត្តក្នុងរយៈពេល១ (មួយ) ឆ្នាំ ក្រោយច្បាប់នេះចូល ជាធរមាន ។

## ច្បាប់អន្តរជាតិស្តីពីបរិយាបន្នការងារសម្រាប់ជនមានពិការភាព

ទោះបីជាមានច្បាប់ជាតិស្តីពីបរិយាបន្នការងារសម្រាប់ជនមានពិការភាពក៏ដោយក៏នៅមានច្បាប់អន្តរជាតិ និងច្បាប់ពាក់ព័ន្ធមួយចំនួនទៀតដែលមានមុំដូចគ្នា ដែលអ្នកបង្កើតច្បាប់ និយោជក និងនិយោជិតអាចទទួលបានអត្ថប្រយោជន៍ពីការស្វែងយល់អំពីច្បាប់នោះ ហើយយកអ្វីដែលអាចកែសម្រួលបាន យកមកអនុវត្តទៅតាមបរិបទជាក់ស្តែងវិញ។

## អនុសញ្ញាស្តីពីសិទ្ធិជនពិការ (CRPD)

មាត្រា ២៧ នៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ (CRPD) គឺផ្តោតទៅលើសិទ្ធិក្នុងការបម្រើការងារ។ បានចែងដូចខាងក្រោម៖

- ជនមានពិការភាពមានសិទ្ធិបម្រើការងារដោយឈរលើមូលដ្ឋានស្មើភាពជាមួយអ្នកដទៃ។
- នេះរាប់បញ្ចូលទាំងសិទ្ធិក្នុងការជ្រើសរើសការងារផ្ទាល់ខ្លួនដើម្បីទទួលបានប្រាក់ឈ្នួលស្មើគ្នាសម្រាប់ការងារស្មើគ្នានិងត្រូវបានការពារពីការរើសអើងនៅកន្លែងធ្វើការ។
- រដ្ឋាភិបាលត្រូវតែចាត់វិធានការដើម្បីធានាថាជនមានពិការភាពអាចទទួលបានឱកាសការងារ នេះរួមបញ្ចូលទាំងការផ្តល់ការបណ្តុះបណ្តាលនិងការគាំទ្រ ក៏ដូចជាធ្វើឱ្យកន្លែងធ្វើការមានការបង្កលក្ខណៈងាយស្រួល (អង្គការសហប្រជាជាតិ, ២០០៦)។

មាត្រា ២៧ គឺជាជំហានដ៏សំខាន់មួយឆ្ពោះទៅរកការធានាថាជនមានពិការភាពមានសិទ្ធិដូចមនុស្សគ្រប់រូប។ វាគឺជាការរំលឹកថាជនមានពិការភាពមានសមត្ថភាពបម្រើការងារ និងរួមចំណែកដល់សង្គម ហើយរដ្ឋាភិបាលមានទំនួលខុសត្រូវក្នុងការធានាថាពួកគេមានឱកាសក្នុងការធ្វើរឿងទាំងអស់នេះ។

## អនុសញ្ញា និងអនុសាសន៍របស់អង្គការពលកម្មអន្តរជាតិ

យោងតាមគោលការណ៍ណែនាំជនមានពិការភាពដែលបោះពុម្ពដោយ ប៊េតទ័រ វើក ឥណ្ឌូនេស៊ី (Better Work Indonesia) អនុសញ្ញាលេខ ១៥៩ និងអនុសាសន៍លេខ ១៦៨ កំណត់ស្តង់ដារអន្តរជាតិសម្រាប់សិទ្ធិជនមានពិការភាពនៅកន្លែងធ្វើការ។ អនុសញ្ញានេះលើក កម្ពស់ឱកាស និងការសម្របសម្រួលស្មើៗគ្នាសម្រាប់កម្មករដែលមានពិការភាពទាក់ទងនឹង សិទ្ធិក្នុងការទទួលបាន ការរក្សាទុក និងការរីកចម្រើនក្នុងការងារ (ប៊េតទ័រ វើក ឥណ្ឌូនេស៊ី - Better Work Indonesia, ២០១៤, ០៤)។

# ជំពូកទី៣៖

# ការបង្កើតអោយមានបរិយាកាសការងារប្រកបដោយបរិយាបន្ន

## ៣.១ ការសម្របសម្រួលសមរម្យនិងការបង្កលក្ខណៈងាយស្រួលនៅកន្លែងការងារ

វាពិតជាសំខាន់ណាស់ក្នុងការបង្កើតអោយមានដំណាក់កាលត្រឹមត្រូវក្នុងការធ្វើអោយការបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាពកាន់តែល្អប្រសើរឡើងតាមរយៈការបន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួល ឧបករណ៍និងបរិក្ខារនៅក្នុងស្ថាប័ន។

## ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់/បរិយាកាសនៃការបង្កលក្ខណៈងាយស្រួល

ជំហាននេះគឺរួមមានការវាយតម្លៃទៅលើកម្រិតនៃការបង្កលក្ខណៈងាយស្រួលរបស់ស្ថាប័ននោះបូករួមជាមួយនឹងធនធានដែលមាននៅក្នុងស្ថាប័ននោះរាប់បញ្ចូលទាំងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (អគារ បន្ទប់ប្រជុំ បន្ទប់ទឹក។ល។) និងផ្នែកពត៌មាន (អក្សរប្រៃលយ៍ កម្មវិធីតិចណូឡូជីដែលជួយដល់អ្នកមានកម្សោយគំហើញនិងភាសាសញ្ញាសម្រាប់អ្នកមានកម្សោយការស្តាប់។ល។) តាមរយៈការវាយតម្លៃបែបនេះ ក្រុមហ៊ុនឯកជន និងស្ថាប័ននិងយល់កាន់តែច្បាស់អំពីកម្រិតនៃការបង្កលក្ខណៈងាយស្រួលនៃស្ថាប័នរបស់ពួកគេក៏ដូចជាអាចចាត់វិធានការចាំបាច់ក្នុងការធ្វើវាអោយកាន់តែល្អប្រសើរ។

## អ្វីដែលត្រូវពិនិត្យ

- ❑ ទីធ្លាសម្រាប់ផ្លាស់ទីចេញចូល
- ❑ ឧបករណ៍ប្រើប្រាស់ក្នុងការិយាល័យ៖ កៅអី តុ កន្លែងទំនេរ សម្ភារៈផ្សេងៗ
- ❑ បន្ទប់ទឹក៖ បង្គន់អនាម័យ កន្លែងទំនេរ
- ❑ ផ្លាកសញ្ញា និងទិសដៅប្រាប់ផ្លូវ
- ❑ កន្លែងស្នាក់នៅ
- ❑ អាហារដ្ឋាន
- ❑ ផ្លូវជម្លៀសបន្ទាន់ និងកណ្តឹងប្រកាសអាសន្ន

បញ្ជីនៃស្ថាប័នដែលធ្វើការងារលើពិការភាព និងដៃគូរដ្ឋាភិបាលសំខាន់ៗ ដែលធ្វើការវាស់ស្ទង់កម្រិតនៃការបង្កលក្ខណៈងាយស្រួលនៃហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

**មជ្ឈមណ្ឌលភ្នំពេញសម្រាប់ការរស់នៅដោយឯករាជ្យ**

អ៊ីមែល: info@ppcil.org
គេហទំព័រ: www.ppcil.org
លេខទូរសារ: (+៨៥៥)២៣ ៦៣២៩ ២១៤
លេខទូរស័ព្ទ: (+៨៥៥)៧៧ ៥០០ ៧០៦

**ក្រុមប្រឹក្សាសកម្មភាពជនពិការ**

អ៊ីមែល: dac@dac.org.kh
គេហទំព័រ: www.dac.gov.kh
លេខទូរស័ព្ទ: (៨៥៥)២៣ ៧២៧ ៤២៨
លេខទូរសារ: (៨៥៥)២៣ ៧២៧ ៤២៦

❑ មធ្យោបាយធ្វើដំណើរ

🔗 **ធនធាន**

**គោលការណ៍ណែនាំមិនមែនបច្ចេកទេសនៃការបង្កលក្ខណៈងាយស្រួល (KH & ENG) ៖** https://bit.ly/nontechnical-guideline

ដែលបង្កើតឡើងដោយក្រុមប្រឹក្សាសកម្មភាពជនពិការ និងមនុស្សជាតិ និងបរិយាបន្ន (HI) អាចត្រូវបានប្រើជាមគ្គុទ្ទេសក៍វាយតម្លៃ។ គោលការណ៍នេះគឺជាបញ្ជីត្រួតពិនិត្យដែលត្រូវបានបង្កើតឡើងតាមជំហានទាំងបួននៃគោលការណ៍ RECU សម្រាប់ការបង្កលក្ខណៈងាយស្រួល (RECU: Reach, Entre, Circulate and Use) ហើយមិនត្រូវការឧបករណ៍ឯកទេស ឬជំនាញណាមួយឡើយ ប៉ុន្តែពឹងផ្អែកលើការ សង្កេត។ វាអាចត្រូវបានធ្វើឡើងដោយនរណាម្នាក់ដែលមានចំណាប់អារម្មណ៍ក្នុងការធ្វើឱ្យប្រសើរឡើងនូវការបង្កលក្ខណៈងាយស្រួលនៃបរិស្ថានរបស់ខ្លួន។ ការវាយតម្លៃគ្របដណ្តប់លើគ្រប់ទិដ្ឋភាពនៃការបង្កលក្ខណៈងាយស្រួលដូចជា (ផ្តេក បញ្ឈរ ទាក់ទងនឹងការទំនាក់ទំនង) ហើយនៅពេលជាមួយគ្នានេះដែរ ក៏ផ្តោតលើប្រភេទនៃឧបសគ្គផ្សេងៗគ្នា (ផ្តេក បញ្ឈរ ទាក់ទងនឹងការទំនាក់ទំនង) សម្រាប់មនុស្សដែលមានពិការភាពប្រភេទផ្សេងៗគ្នា (រាងកាយ គំហើញ , ការស្តាប់, ផ្លូវចិត្ត និងសតិបញ្ញា), មនុស្សចាស់, កុមារ, ស្ត្រីមានផ្ទៃពោះ។ល។

## ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

បន្ទាប់ពីទទួលបានតាមរយៈការវាយតម្លៃដំបូងនៃហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅតាមស្ថាប័ន ស្ថាប័ននោះត្រូវបានលើកទឹកចិត្តឱ្យបង្កើតនូវការសម្របសម្រួលធ្វើឡើងដើម្បីបង្កលក្ខណៈងាយស្រួលដល់ជនមានពិការភាព។

សកម្មភាពអាចចាប់ផ្តើមពីតូចទៅ៖

- ដាក់ជាសញ្ញាសម្គាល់ពីទិសដៅនៃទីតាំងនៃច្រកចេញចូលមានលក្ខណៈ

ងាយស្រួល, ជណ្ដើរយន្ត, បន្ទប់ទឹក, និងគ្រឿងបរិក្ខារផ្សេងៗទៀត។ ផ្លាកសញ្ញា គួរតែអាចមើលឃើញបានច្បាស់ អានបាន និងមានគ្រប់គ្រាន់ពេញអគារ ដោយប្រើ និមិត្តសញ្ញា និងពណ៌ដែលត្រូវបានទទួលស្គាល់និងយល់ជាសកលដោយជនមានពិការភាពប្រភេទផ្សេងៗគ្នា។




- ដំឡើងនូវជម្រាល, បង្កាន់ដៃ, ទ្វារស្វ័យប្រវត្តិ, និងជណ្ដើរយន្ត នៅតាមទីតាំងសំខាន់ៗ ដើម្បីបង្កលក្ខណៈងាយស្រួលដល់អ្នកប្រើប្រាស់រទេះរុញ។
- កែសម្រួលបង្គន់មួយឱ្យទៅជាបង្គន់ដែលមានភាពងាយស្រួលសម្រាប់ជនមានពិការភាព ដោយសម្គាល់ដោយរូបរទេះរុញនិងផ្ដល់នូវមុខងារដូចជា មានទ្វារធំ ដែកសម្រាប់ទប់ និងកន្លែងលាងដៃដែលមានកម្ពស់ទាប។

**🔗ធនធាន៖ ស្តង់ដារនៃហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលនៅប្រទេសកម្ពុជា**

- **<u>ស្តង់ដារបច្ចេកទេស</u>នៃហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួ (KH & ENG)៖** https://bit.ly/technical-standard-physical-accessibility
  បង្កើតឡើងដោយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC-SG) ក្រោមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ផ្ដល់ព័ត៌មានលម្អិតអំពីលក្ខណៈបច្ចេកទេសសម្រាប់ហេដ្ឋារចនាសម្ព័ន្ធបង្កលក្ខណៈងាយស្រួលសម្រាប់អគារសាធារណៈទាំងអស់នៅក្នុង កម្ពុជា។ សន្លឹកពត៌មាន និងគំនូរជីវចលវីដេអូដែលផលិតដោយ **<u>ACCESS</u>** ក៏ត្រូវបានរួមបញ្ចូលផងដែរ។

- **<u>គោលការណ៍ណែនាំមិនមែនបច្ចេកទេសនៃការបង្កលក្ខណៈងាយស្រួល (KH & ENG) ៖</u>** https://bit.ly/nontechnical-guideline ដែលបង្កើតឡើងដោយក្រុមប្រឹក្សាសកម្មភាពជនពិការ និងមនុស្សជាតិ និងបរិយាបន្ន (HI) អាចត្រូវបានប្រើជាមគ្គុទ្ទេសក៍វាយតម្លៃ។ គោលការណ៍នេះគឺជាបញ្ជីត្រួតពិនិត្យដែលត្រូវបានបង្កើតឡើងតាមជំហានទាំងបួននៃគោលការណ៍ RECU សម្រាប់ការបង្កលក្ខណៈងាយស្រួល (RECU: Reach, Entre, Circulate and Use) ហើយមិនត្រូវការឧបករណ៍ឯកទេស ឬជំនាញណាមួយឡើយ ប៉ុន្តែពឹងផ្អែកលើការសង្កេត។ វាអាចត្រូវបានធ្វើឡើងដោយនរណាម្នាក់ដែលមានចំណាប់អារម្មណ៍ក្នុងការធ្វើឱ្យប្រសើរឡើងនូវការបង្កលក្ខណៈងាយស្រួលនៃបរិស្ថានរបស់ខ្លួន។ ការវាយតម្លៃគ្របដណ្តប់លើគ្រប់ទិដ្ឋភាពនៃការបង្កលក្ខណៈងាយស្រួលដូចជា (ផ្តេក បញ្ឈរ ទាក់ទងនឹងការទំនាក់ទំនង) ហើយនៅពេលជាមួយគ្នានេះដែរក៏ផ្តោតលើប្រភេទនៃឧបសគ្គផ្សេងៗគ្នា (ផ្តេក បញ្ឈរ ទាក់ទងនឹងការទំនាក់ទំនង) សម្រាប់មនុស្សដែលមានពិការភាពប្រភេទផ្សេងៗគ្នា (រាងកាយ គំហើញ , ការស្តាប់, ផ្លូវចិត្ត និងសតិបញ្ញា), មនុស្សចាស់, កុមារ, ស្ត្រីមានផ្ទៃពោះ។ល។

## បង្កើតឱ្យមាននូវទម្រង់បែបបទសម្រាប់តម្រូវការនៃការសម្របសម្រួល

មធ្យោបាយដ៏ល្អបំផុតដើម្បីយល់ពីតម្រូវការរបស់បុគ្គលិកមានពិការភាពគឺត្រូវស្តាប់នូវសំណើរដោយផ្ទាល់ពីពួកគេ។ ទម្រង់បែបបទសម្រាប់តម្រូវការនៃការសម្របសម្រួលគឺជាឯកសារដែលផ្តល់សិទ្ធឱ្យជនមានពិការភាពនៅកន្លែងធ្វើការធ្វើការស្នើសុំការសម្របសម្រួលសមរម្យពីស្ថាប័នរបស់គាត់ដោយផ្អែកទៅលើទម្រង់លក្ខណៈនៃការងាររបស់គាត់និងជំនួយដែលគាត់ត្រូវការក្នុងការជួយគាត់ក្នុងការធ្វើការងារ។

ទម្រង់បែបបទនេះរួមបញ្ចូលនូវពត៌មានដូចខាងក្រោម៖

- ឈ្មោះរបស់បុគ្គលិកនិងពត៌មានទំនាក់ទំនងរបស់គាត់
- ឈ្មោះរបស់អ្នកតំណាងបុគ្គលិកដើម្បីទាក់ទងក្នុងគ្រាមានអាសន្ន

- ប្រភេទនិងកម្រិតពិការភាពរបស់បុគ្គលិកនិងកម្រិតនៃការប៉ះពាល់នៃពិការភាពរបស់គាត់ទៅលើការងាររបស់គាត់
- ការព្យាបាលជម្ងឺរបស់បុគ្គលិក ការប្រើប្រាស់ថ្នាំពេទ្យ ឬការប្រើប្រាស់ឧបករណ៍ជំនួយ (ប្រសិនបើមាន)
- ជម្រើសនៃការសម្របសម្រួលសមរម្យរបស់បុគ្គលិក រួមមានការធ្វើបទបង្ហាញ ការផ្តល់ការឆ្លើយតប បរិបទការងារ ពេលវេលា កាលវិភាគ ឬជំនាញក្នុងការរៀបចំ។
- (ប្រសិនបើមាន) ឯកសារយោងរបស់បុគ្គលិកដូចជាលិខិតពេទ្យបញ្ជាក់ពីការព្យាបាលជម្ងឺដែលចេញដោយគ្រូពេទ្យឯកទេស របាយការណ៍វាយតម្លៃឬទម្រង់បែបបទសុំការសម្របសម្រួលសមរម្យពីកន្លែងការងារចាស់។

ទម្រង់បែបបទនេះគួរតែបញ្ជូនទៅកាន់ផ្នែកធនធានមនុស្ស ឬផ្នែករដ្ឋបាលដើម្បីចាត់ចែងរៀបចំទម្រង់បែបបទការសម្របសម្រួលសមរម្យនិងធ្វើការរៀបចំផ្តល់អោយ។ ខាងការិយាល័យនោះនឹងធ្វើការត្រួតពិនិត្យនូវទម្រង់បែបបទនោះនិងឯកសារយោងផងដែរដើម្បីធ្វើការកំណត់នូវលក្ខន្តិកៈក្នុងការទទួលបានការសម្របសម្រួលសមរម្យក៏ដូចជាសមត្ថភាពដែលស្ថាប័នអាចផ្តល់អោយបាន។ គំរូនៃទម្រង់តម្រូវការសម្របសម្រួលសមរម្យនេះត្រូវបានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី៥។ គួរជ្រាបផងដែរថាតម្រូវការការសម្របសម្រួលសមរម្យនិងពត៌មានដែលភ្ជាប់គួរតែរក្សាអោយមាននូវការសម្ងាត់ដើម្បីផ្តល់នូវឯកជនភាពសម្រាប់បុគ្គលដែលធ្វើការស្មើ។

## ៣.២ គោលការណ៍កន្លែងការងារនិងការអនុវត្តដែលជម្រុញបរិយាបន្ន

គោលការណ៍នៃកន្លែងការងារអាចខុសគ្នាពីស្ថាប័នមួយទៅស្ថាប័នមួយដូច្នេះហើយវាមានសារៈសំខាន់ដែលក្រុមហ៊ុននីមួយបង្កើតគោលការណ៍ការងារដែលគាំទ្របរិយាបន្នពិការភាព

ដោយផ្ទែទៅតាមលក្ខណៈនៃស្ថាប័ន ប្រភេទពិការភាព តំណែង ការិយាល័យ និងផ្សេងៗទៀត ដើម្បីប្រាកដគោលការណ៍គាំទ្របរិយាបន្នពិការភាពនោះអាចសម្រេចបាន។ ខាងក្រោមនេះ គឺជាសកម្មភាពគោលមួយចំនួនដែលត្រូវបានណែនាំអោយអនុវត្តសម្រាប់ការទទួលបាន បរិយាបន្នពិការភាពដែលមានប្រសិទ្ធភាព៖

- កំណត់នូវគោលដៅច្បាស់លាស់សម្រាប់ភាពចម្រុះនិងបរិយាបន្ន។ ជួយដល់បុគ្គលិកនៅក្នុងស្ថាប័នក្នុងការស្វែងយល់អំពីសារៈសំខាន់នៃគោលការណ៍ទាំងនេះនិងបង្ហាញអោយយល់អំពីអត្ថន័យនៃភាពជាអ្នកដឹកនាំដែលមានឆន្ទៈជម្រុញបរិយាបន្ន។
- ពង្រឹងនូវបរិយាកាសដែលបង្កអោយបុគ្គលិកគ្រប់គ្នាមានផាសុកភាពក្នុងការធ្វើជាខ្លួនឯងនិងមានអារម្មណ៍ថាពួកគេត្រូវបានរួមបញ្ចូលដោយមិនខ្វល់អំពីប្រវត្តិរូបនិងអត្តសញ្ញាណរបស់ពួកគេ។
- ជម្រុញអោយមានបរិយាកាសការងារដែលប្រកបដោយភាពស្មើគ្នា និងបរិយាបន្ន ត្រូវប្រាកដថាបុគ្គលិកទាំងអស់ គ្រប់ថានៈនិងតួនាទីសុទ្ធតែទទួលបាននូវបរិយាកាសការងារដែលប្រកបដោយភាពស្មើគ្នានិងប្រកបដោយបរិយាបន្នដោយមិនខ្វល់ពីពណ៌សម្បុរ សញ្ជាតិ យេនឌ័រ និន្នាការផ្លូវភេទ និងសាសនារបស់ពួកគេ ឬកត្តាផ្សេងទៀត។
- ផ្តល់អោយបុគ្គលិកនូវចំនេះដឹងដែលពួកគេត្រូវការក្នុងការជៀសវាងនូវភាពលំអៀងរបស់ពួកគេ។ ជួយបុគ្គលិកក្នុងការធ្វើការសម្រេចចិត្តដែលប្រកបដោយតម្លាភាពនិងសមហេតុផល។
- អបអរសាទរនូវភាពសម្បូរបែបនិងភាពចម្រុះនៅក្នុងកន្លែងការងារ។ ទទួលយកដោយរីករាយនូវភាពចម្រុះដោយត្រូវគិតថាវាជាគុណសម្បត្តិមួយដែលជួយក្នុងការប្រកួតប្រជែងភាពឆ្នៃប្រឌិតក្នុងកន្លែងការងារ (Pedulla, 2020)។

# ការលើកកម្ពស់នូវការយល់ដឹងនិងការទទួលយក

ពិការភាពអាចមានច្រើនរូបភាពនិងខុសៗគ្នា ទាំងអាចមើលឃើញផងនិងមិនអាចមើលឃើញផង ដូច្នេះហើយការសន្មត់ទុកជាមុនអាចមានពីជនដែលមិនមានពិការភាព។ ដូច្នេះហើយទើបការរើសអើងអាចកើតចេញពីការមិនយល់ដឹង ហើយវាអាចចាត់ទុកជាឧបសគ្គបែបអាកប្បកិរិយា និងឧបសគ្គបែបស្ថាប័ន ដូចដែលបានលើកឡើងនៅក្នុងជំពូកទី១។ ការលើកកម្ពស់ការយល់ដឹងនិងការទទួលយកបរិយាបន្ននៅក្នុងស្ថាប័នមួយ ទាំងនយោជិតនិងនយោជកគឺមានសារៈសំខាន់ណាស់ក្នុងការបង្កើតអោយមាននូវបរិយាកាសការងារមួយដែលប្រកបដោយភាពវិជ្ជមាននិងការគាំទ្រពេញលេញ ដែលគោរពទទួលស្គាល់នូវភាពចម្រុះព្រមទាំងជម្រុញអោយមាននូវសណ្តាប់ធ្នាប់សង្គម។ តាមរយៈការលើកកម្ពស់ការយល់ដឹងនិងទទួលយកបរិយាបន្ន ក្រុមហ៊ុនឯកជនក៏បានចូលរួមក្នុងការអនុវត្តនូវអនុសញ្ញាស្តីពីសិទ្ធជនមានពិការភាព និងគោលដៅអភិវឌ្ឍប្រកបដោយចីរភាព។ សកម្មភាពផ្សេងៗទៀតអាចនឹងត្រូវអនុវត្តបន្ថែមដើម្បីចាប់ផ្តើមដំណើរបរិយាបន្ននេះ។

## ផ្តល់វគ្គបណ្តុះបណ្តាលផ្នែកបរិយាបន្នពិការភាពដល់បុគ្គលិកគ្រប់កម្រិត

ទាំងនយោជិតនិងនយោជកសុទ្ធសឹងតែអាចទទួលបាននូវគុណប្រយោជន៍ពីវគ្គបណ្តុះបណ្តាលបរិយាបន្នពិការភាពដើម្បីជួយអោយពួកគេយល់ដឹងកាន់តែស៊ីជម្រៅពីតម្រូវការរបស់ជនមានពិការភាព និងដើម្បីបង្កើតនូវការយល់ចិត្តជនមានពិការភាពនៅក្នុងស្ថាប័នរួម។

ប្រធានបទវគ្គបណ្តុះបណ្តាលអាចមានដូចខាងក្រោម៖

- សេចក្តីណែនាំទូទៅនៃពិការភាព
- ឧបសគ្គក្នុងការទទួលបានបរិយាបន្ន
- សីលធម៌នៃពិការភាព/ការប្រើប្រាស់ភាសាសមរម្យ។



## ការបណ្ដុះបណ្ដាលគ្រូបង្គោល

សិក្ខាសាលាបែបនេះអាចជួយដល់បុគ្គលិកក្នុងការស្វែងយល់នូវកម្រិតបច្ចុប្បន្ននៃក៏ដូចជាឧបសគ្គប្រឈមទាំងឡាយដែលស្ថាប័នកំពុងជួបប្រទះ ដោយក្នុងពេលជាមួយគ្នានោះដែររួមបញ្ចូលបុគ្គលិកស្ថាប័ននៅក្នុងដំណាក់កាលនៃគម្រោងបរិយាបន្នពិការភាព។ នេះគឺអាចធ្វើបានតាមរយៈគម្រូនៃការបណ្ដុះបណ្ដាលលើគ្រូបង្គោលដើម្បីប្រាកដថាមាននិរន្តភាពនៅពេលដែលក្រុមហ៊ុនទាំងឡាយផ្ដល់នូវការបណ្ដុះបណ្ដាលដែលជាផ្នែកមួយនៃការរៀបចំបម្រុងបុគ្គលិកថ្មីចូលក្នុងស្ថាប័ន។

មានវគ្គសិក្សាអនឡាញដោយឥតគិតថ្លៃមួយចំនួន អាចចូលមើលលើពិការភាពនៅកន្លែងការងារៈ ទស្សនៈសកល ដោយ ITCILO។ លើសពីនេះទៅទៀត ស្ថាប័នដែលមាននៅក្នុងឧបសម្ព័ន្ធទី១ មានដូចជា សហគ្រាសសង្គម អេដ្យាលយ៍ អង្គការជនពិការកម្ពុជា អង្គការសកម្មភាពប្រជាជនដើម្បីអភិវឌ្ឍនបរិយាបន្ន សុទ្ធតែជាស្ថាប័នដែលអាចទាក់ទងបានក្នុងគោលបំណងស្នើសុំការបណ្ដុះបណ្ដាលបរិយាបន្នពិការភាពសម្រាប់ស្ថាប័នឯកជនទូទៅ។

- ធ្វើការតម្រង់ទិសបុគ្គលិកលើផែនការយុទ្ធសាស្រ្តជាតិស្តីពីពិការភាព (ឆ្នាំ២០១៩-២០២៣) ភ្ជាប់ជាមួយនឹងយុទ្ធសាស្រ្តបរិយាបន្នពិការភាព ។ ស្ថាប័នមួយចំនួនដែលធ្វើលើពិការភាព អ្នកជំនាញផ្នែកពិការភាព ឬក្រសួងពាក់ព័ន្ធ (ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា/ក្រុមប្រឹក្សាសកម្មភាពជនពិការកម្ពុជា) ក៏អាចផ្ដល់ជាការគាំទ្រតាមរូបភាពនៃការជួយតម្រង់ទិសបុគ្គលិកគ្រប់រូបទៅលើគោលនយោបាយថ្នាក់ជាតិ និងឆន្ទះអន្តរជាតិ។



**ចាត់តួនាទីច្បាស់លាស់លើបុគ្គលរូបណាមួយដែលទទួលភារកិច្ចលើបញ្ហាពិការភាពសម្រាប់ស្ថាប័ន:**

ត្រូវចាត់ចែងអោយមានបុគ្គលបង្គោលម្នាក់ដែលមានតួនាទីលើបញ្ហាទាំងទងនឹងពិការភាពសម្រាប់ស្ថាប័ននោះដើម្បីអាចធានាបានថាការអនុវត្តនូវគោលការណ៍គាំទ្របរិយាបន្នពិការភាពប្រកបទៅដោយរលូន និងដើម្បីបង្កើតនូវយន្តការសម្រាប់បុគ្គលិកមានពិការភាព។

**បង្កើតអោយមាននូវគោលការណ៍គ្មានការរើសអើងក្នុងស្ថាប័ន:**

គោលការណ៍នោះគួរតែប្រាកដថាជនមានពិការភាពអាចទទួលបានឱកាសស្មើគ្នាក្នុងការទទួលបានឱកាសការងារ និងឱកាសក្នុងការឡើងតួនាទីដូចទៅនឹងជនដែលគ្មានពិការភាពដែរ និងត្រូវប្រាកដថាពួកគេមិនទទួលរងនូវការរើសអើងគ្រប់ទម្រង់ ឬការយៀយីបៀតបៀនដោយសារតែពិការភាពរបស់ពួកគេ។

គោលការណ៍ទាំងនោះគួរតែផ្តល់នូវការសម្របសម្រួលសមរម្យនិងការគាំទ្រសម្រាប់ជនមានពិការភាពដើម្បីចូលរួមយ៉ាងពេញលេញនៅក្នុងស្ថាប័ននិងអោយពួកគេមានអារម្មណ៍ធូរស្រាលស្របពេលដែលពួកគេកំពុងអនុវត្តគោលការណ៍ទាំងនោះ។ ដើម្បីប្រាកដថាគោលការណ៍នោះមានប្រសិទ្ធភាព លទ្ធផលប្រឈមគួរតែពន្យល់និងប្រាប់អោយច្បាស់តាំងពីដំណាក់កាលចាប់ផ្តើម ហើយវិធានការណ៍ចាំបាច់សម្រាប់លទ្ធផលប្រឈមក៏គួរតែដាក់ចេញទៅតាមការបំពាននូវគោលការណ៍។

**ធ្វើការវាស់ស្ទង់នូវសមត្ថភាពរបស់ស្ថាប័នក្នុងការអនុវត្តបរិយាបន្ន:**

ជំហានសំខាន់បន្ទាប់នៃគម្រោងបរិយាបន្នគឺការវាស់ស្ទង់នូវបរិក្ខារដែលមានស្រាប់ និងធនធានមនុស្សដែលត្រូវការដើម្បីអនុវត្តគម្រោងបរិយាបន្ន។ វាអាចជួយដល់ការកំណត់នូវអ្វីដែលមានស្រាប់ និងអ្វីដែលត្រូវសម្របឬកែប្រែ។

# ៤. ការជ្រើសរើសបុគ្គលិកដែលមានពិការភាព

## ៤.១ ដំណើរការជ្រើសរើសបុគ្គលិកប្រកបដោយបរិយាបន្នពិការភាព

ជាទូទៅការប្រកាសរើសបុគ្គលិកភាគច្រើនគឺតែងតែមើលរំលងជនមានពិការភាព ពីព្រោះការជ្រើសរើសបុគ្គលិកដែលមាន "កាយសម្បទាមាំមួន" គឺបានចាត់ទុកជារឿងធម្មតា ហើយភាគច្រើនគឺកើតឡើងដោយសារតែភាពលំអៀងដោយមិនដឹងខ្លួន។ តាមរយៈការមិនរួមបញ្ចូលនូវសេចក្តីពណ៌នានៃពត៌មានជ្រើសរើសបុគ្គលិកដែលជម្រុញបរិយាបន្នពិការភាព ទោះបីជាមានបំណងឬគ្មានបំណង វាអាចបំបាក់ទឹកចិត្តជនមានពិការភាពក្នុងការដាក់ពាក្យការងារនោះតាំងពីដំបូង។

### បញ្ជាក់និងជម្រុញទឹកចិត្តដល់ក្រុមគោលដៅ:

ក្នុងបរិបទនេះយើងសំដៅដល់ជនមានពិការភាព។ មិនថានៅលើរូបភាពនៃការប្រកាសជ្រើសរើសបុគ្គលិក ឬតាមការសរសេរត្រូវប្រាកដថាស្ថាប័ននោះបានបញ្ចូលនូវសារអំពាវនាវសម្រាប់អោយជនមានពិការភាពដាក់ពាក្យ។ ឧទាហរណ៍ "ស្ត្រីនិងជនមានពិការភាពត្រូវបានលើកទឹកចិត្តអោយដាក់ពាក្យការងារនេះ"។

## ផ្ដល់អោយអស់នូវពត៌មានអំពីការងារនៅក្នុងសេចក្ដីបរិយាយនៃតួនាទីការងារ:

នយោជកត្រូវប្រាកដថាគ្រប់ឋានៈនិងតួនាទីដែលរំពឹងទុកពីបេក្ខជនគឺត្រូវតែបង្ហាញអោយអស់និងច្បាស់លាស់។ មិនគួរធ្វើការបង្ហាញពត៌មានតែមួយផ្នែកទេ។ វាពិតជាសំខាន់ណាស់ក្នុងការបញ្ជាក់អោយច្បាស់នូវប្រភេទនៃពិការភាពដែលត្រូវជាមួយហ្នឹងការងារដើម្បីងាយស្រួលអោយស្ថាប័ននោះរៀបចំប្រភេទនៃការសម្របសម្រួលសមរម្យដែលចាំបាច់សម្រាប់បេក្ខជន ហើយដើម្បីអោយបេក្ខជនដឹងច្បាស់អំពីការរំពឹងទុកពីស្ថាប័នមុនពេលចូលដល់វគ្គសម្ភាសន៏ការងារ។

## ត្រូវមានឆន្ទះក្នុងការផ្ដល់ការសម្របសម្រួលសមរម្យ:

ការសម្របសម្រួលសមរម្យត្រូវតែផ្ដល់ជូនដោយនយោជកទៅកាន់នយោជិកមានពិការភាពនៅពេលដែលជ្រើសរើសបុគ្គលិកមានពិការភាពពីព្រោះវាជួយក្នុងការធ្វើការងាររបស់បុគ្គលិកនោះ។ លើសពីនេះទៅទៀតរូបភាពផ្សេងទៀតនៃការសម្របសម្រួលសមរម្យគួរតែផ្ដល់អោយបេក្ខជនមានពិការភាពនៅវគ្គសម្ភាសន៏ ឧទាហរណ៏ ការផ្ដល់ថ្លៃធ្វើដំណើរអោយបេក្ខជនមានពិការភាពដើម្បីទៅសម្ភាសន៏។ ដំណើរការនៃការជ្រើសរើសបុគ្គលិកនិងការសម្ភាសន៏គួរតែសម្របនិងកែប្រែដោយផ្អែកទៅលើតម្រូវការរបស់បេក្ខជនមានពិការភាព។ សម្រាប់ពត៌មាននិងឯកសារយោងបន្ថែមនៃការសម្របសម្រួលសមរម្យ នយោជកអាចមើលនៅចំនុច៣.១នៅក្នុងមគ្គុទេសន៏ណែនាំនេះ។

## ត្រូវបើកចិត្តក្នុងការផ្ដល់ឱកាស:

នយោជកគួរតែអោយឱកាសដល់បេក្ខជនមានពិការភាពក្នុងការបង្ហាញសមត្ថភាពការងាររបស់ពួកគេតាមរយៈរូបភាពនៃការសាកល្បងការងាររយៈពេលពី២អាទិត្យយ៉ាងតិចរហូតដល់៣ខែ ដោយផ្ដល់ប្រាក់កម្រៃ។ កម្មវិធីហាត់ការការងារក៏គួរតែអាចផ្ដល់អោយ។

**ទាក់ទងទៅកាន់ស្ថាប័នដែលធ្វើការងារលើពិការភាព ឬក្រសួងដែលពាក់ព័ន្ធសម្រាប់ជំនួយផ្នែកបច្ចេកទេស:**

វាអាចមានប្រសិទ្ធភាពជាងក្នុងការទំនាក់ទំនងទៅកាន់ជនមានពិការភាពផ្ទាល់ពេលជ្រើសរើសបុគ្គលិកពីព្រោះជារឿយៗ ស្ថាប័នទាំងនេះស្គាល់ជនមានពិការភាពច្បាស់ជាងគេ ហើយពួកគេអាចនឹងទទួលបាននូវជំនាញធ្វើការងារ ឬការរឹកហាត់ការងារសម្រាប់ការងារជាក់ស្តែង។ ទីភ្នាក់ងាររដ្ឋាភិបាលមួយចំនួនដូចជា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា ជាឧទាហរណ៍ អាចជួយស្ថាប័នឯកជនក្នុងការស្វែងរកនិងជ្រើសរើសបេក្ខជនមានពិការភាព។ ដូច្នេះហើយទើបវាមានសារៈសំខាន់សម្រាប់ស្ថាប័នឯកជនក្នុងការបង្កើតអោយមាននូវទំនាក់ទំនងល្អជាមួយអង្គភាពដែលបានរៀបរាប់ខាងលើនេះ។

**សម្រាប់ពត៌មានទំនាក់ទំនងទៅកាន់ក្រសួងដែលពាក់ព័ន្ធដែលធ្វើការលើវិស័យពិការភាព សូមមើលទៅលើចំនុច ឧបសម្ព័ន្ធទី១ នៃមគ្គុទេសន៍ណែនាំនេះ។**

## ៥. ករណីសិក្សានៃបរិយាបន្នការងារក្នុងក្រុមហ៊ុនឯកជនក្នុងស្រុកមួយ



# សមត្ថភាពជាជាងពិការភាព : និយោជកបកស្រាយពីគុណតម្លៃក្នុងការជ្រើសរើសបុគ្គលិកដែលមានពិការភាព



«...ពួកគេមានការខិតខំប្រឹងប្រែងនិងយកចិត្តទុកដាក់ខ្ពស់ ព្រមទាំងបំពេញការងារបានល្អ។ និយាយជារួម ខ្ញុំគ្មានការព្រួយបារម្ភចំពោះសមត្ថភាពការងាររបស់ពួកគាត់ឡើយ ដោយសារតែគាត់មានភាពអំណត់ និងគោរពតួនាទីខ្លួនបានល្អ។» លោក **ស៊ីម មករា** អគ្គនាយកក្រុមហ៊ុន SM Eco Development (SMED) បកស្រាយពីបទពិសោធន៍ការងារជាមួយបុគ្គលិកដែលមានពិការភាព

**លោក ស៊ីម មករា** ជាអគ្គនាយកក្រុមហ៊ុន **SM Eco Development (SMED)** ដែលធ្វើការវិនិយោគលើវិស័យអចលនទ្រព្យបែបទេសចរណ៍មានដូចជាការដាំដុះ ចិញ្ចឹមសត្វ និងការរស់នៅបែបផ្ទះលំហែជាដើម។ បង្កើតឡើងនៅក្នុងអំឡុងការរាតត្បាតជាសកលនៃជំងឺកូវីដ ១៩ ក្រុមហ៊ុនមានចក្ខុវិស័យក្នុងការកែប្រែដីទំនេរអោយក្លាយជាអាជីវកម្មដែលមានផលចំណេញ។ក្នុងពេលបច្ចុប្បន្នក្រុមហ៊ុនកំពុងផ្តល់ឱកាសការងារជូនដល់បុគ្គលិកសរុប ២៤នាក់ ស្រី ៧នាក់ និងប្រុសចំនួន ១៤នាក់ សម្រាប់ទាំងទីតាំងការិយាល័យ និងទីតាំងអចលនទ្រព្យ។ ក្នុងនោះផងដែរបុគ្គលិកចំនួន៣រូបដែលមានមុខតំណែងផ្នែករដ្ឋបាលនិងផ្នែកលក់ជាជនដែលមានពិការភាព។ សម្រាប់ការផ្តល់ឱកាសការងារដល់ជនដែលមានពិការភាព **លោក មករា** បានសម្តែងអារម្មណ៍ជ្រាលជ្រៅដោយហេតុថាភរិយារបស់លោកក៏មានពិការភាពជើងផងដែរ។ លោកយល់ច្បាស់ពីទុក្ខលំបាករបស់ពួកគេដូច្នេះហើយទើបការផ្តល់ការងារដល់ជនដែលមានពិការភាពគឺជាការបង្កើតឱកាសអោយពួកគេបង្ហាញពីសមត្ថភាពក៏ដូចជាបង្កើនប្រាក់ចំណូលផ្ទាល់ខ្លួន។សកម្មភាពរបស់លោកក៏ចាត់ទុកជាការអនុវត្តដែលអនុលោមត្រឹមត្រូវតាមទំនួលខុសត្រូវរបស់ក្រុមហ៊ុនចំពោះផែនការយុទ្ធសាស្ត្រជាតិពិការភាពរបស់ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាផងដែរ។

**លោក មករា** បានអោយដឹងបន្ថែមពីបទពិសោធន៍ជ្រើសរើសបុគ្គលិកដែលមានពិការភាពថាការជ្រើសរើសសម្រាប់ក្រុមហ៊ុនរបស់លោកច្រើនតែកើតឡើងតាមរយៈបណ្តាញជនដែលមានពិការភាពដែលភរិយារបស់លោកបានចូលរួមធ្វើសកម្មភាពជាមួយ។ ក្រៅពីនេះ លោកក៏បានប្រើប្រាស់បណ្តាញសង្គមក្នុងអំឡុងពេលស្វែងរកបុគ្គលិក ដោយជារឿយៗលោកតែងតែផ្តល់អាទិភាពដល់បេក្ខជនដែលមានពិការភាពមុនគេ។

> «ជាការពិត បេក្ខជនមានពិការភាពដែលដាក់ពាក្យធ្វើការមានភាគរយតិចតួចមែនទែន។ ដូច្នេះ ក្នុងករណីដែលមានការដាក់ពាក្យពីពួកគាត់ ខ្ញុំតែងតែទទួលពួកគេភ្លាមៗដូចគ្នា។ សម្រាប់ខ្ញុំ ខ្ញុំច្រើនតែអោយតម្លៃលើសមត្ថភាពជាក់ស្តែងជាជាងកម្រិតអប់រំរបស់ពួកគេ។»
> **លោក មករា** បន្ថែម

ទាក់ទងនឹងការវាយតម្លៃលោកតែងអោយពិន្ទុទៅតាមសមត្ថភាពនិងការគ្រប់គ្រងការងារផ្ទាល់ខ្លួនដែលជាហេតុធ្វើអោយលោកមានការភ្ញាក់ផ្អើលបន្ទាប់ពីរួមការងារជាមួយបុគ្គលិកដែលមានពិការភាព។

> «ខ្ញុំមើលឃើញថាគាត់មានការប្តេជ្ញាចិត្តខ្លាំងជាងបុគ្គលិកដែលគ្មានពិការភាព។ ពួកគាត់មានការខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់ខ្ពស់ព្រមទាំងបំពេញការងារបានល្អ។ និយាយជារួម ខ្ញុំគ្មានការព្រួយបារម្ភចំពោះសមត្ថភាពការងាររបស់ពួកគាត់ឡើយ ដោយសារតែគាត់មានភាពអំណត់ និងគោរពតួនាទីខ្លួនបានល្អ។» **លោក មករា** បន្ថែម

ការគ្រប់គ្រងបុគ្គលិកដែលមានពិការភាពមិនមែនជាបញ្ហាសម្រាប់លោកនោះឡើយ ព្រោះការបែងចែកការងារគឺធ្វើឡើងទៅតាមសមត្ថភាពនិងលទ្ធភាពរបស់ពួកគេស្របពេលដែលក្រុមហ៊ុននៅតែបន្តខិតខំសម្របសម្រួលទៅតាមតម្រូវការ និងព្យាយាមដោះស្រាយរាល់បញ្ហាដែលពួកគេជួបប្រទះ។

ជាក់ស្តែងក្រុមហ៊ុនរបស់លោកទើបតែអនុវត្តការសម្របសម្រួលប្រកបដោយបរិយាបន្នចំពោះបុគ្គលិកដែលមានពិការភាពតាមរូបភាពផ្សេងៗដូចជាការសាងសង់ជំរាលបន្ទប់ទឹកកែលម្អផ្លូវឆ្លងកាត់និងផ្ទះបាយដើម្បីផ្តល់ភាពងាយស្រួលដល់ពួកគាត់។ លើសពីនេះទៀត លោក មករា តែងតែអញ្ជើញគ្រូបង្គោលមកបង្ហាត់បង្រៀនជំនាញផ្សេងៗឬបញ្ជូនបុគ្គលិកទៅហ្វឹកហាត់តាមរយៈសិក្ខាសាលានានាដូចគ្នា។ចំពោះទំនាក់ទំនងរវាងបុគ្គលិកដែលមាន និងគ្មានពិការភាពបានធ្វើអោយបរិយាកាសកន្លែងការងារមានភាពប្រសើរ និងមានការចុះសម្រុងគ្នាបានយ៉ាងល្អ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើមានការរើសអើងកើតឡើងលោកនឹងចាត់វិធានការណែនាំអប់រំដើម្បីអោយពួកគេផ្លាស់ប្តូររបៀបទំនាក់ទំនងអោយបានល្អសមស្របជាងមុន ពង្រឹងទស្សនទាននៃសមត្ថភាពជាជាងពិការភាព និងការយល់ដឹងបន្ថែមអំពីវិស័យនេះដើម្បីបង្កើតអោយមានបរិយាបន្ននៅក្នុងកន្លែងការងារ។ នៅថ្ងៃខាងមុខ លោកមានគម្រោងស្វែងរកបុគ្គលិកដែលមានពិការភាពបន្ថែមទៀត បើទោះជាសព្វថ្ងៃក្រុមហ៊ុនមានបុគ្គលិកគ្រប់គ្រាន់ក៏ដោយ។

ដូចដែលបានឡើងខាងលើលោកទទួលស្គាល់ពីវិស័យពិការភាពហើយមានបំណងជួយពួកគេតាមលទ្ធភាពដែលលោកមាន។តាមរយៈការយល់អាស្រ័យរបស់ជនដែលមានពិការភាព លោក មករា នឹងវាយតម្លៃដោយផ្អែកលើបុគ្គលិកលក្ខណៈ និងការអនុវត្តការងាររបស់ពួកគេតែប៉ុណ្ណោះ។ពួកគេនឹងទទួលបានអាទិភាពប្រសិនបើពួកគេមានសមត្ថភាពនិងជំនាញពិតប្រាកដដែលលោកត្រូវការ។ជាចុងក្រោយលោក សូមធ្វើការលើកទឹកចិត្តជនដែលមានពិការភាពទាំងអស់អោយចាប់យកជំនាញច្បាស់លាស់មួយព្រោះវាជាមធ្យោបាយតែមួយគត់ដែលអាចអោយពួកគេអភិវឌ្ឍខ្លួនឯងបាន។

> «ទោះបីជាអ្នកមានពិការភាព ប៉ុន្តែអ្នកនឹងជោគជ័យនៅក្នុងស្ថាប័ន ឬក្រុមហ៊ុនណាមួយព្រោះបេះដូង និងសមត្ថភាពមានតម្លៃជាងរូបរាងកាយរបស់អ្នក។ ទទួលស្គាល់ការពិតរបស់ខ្លួនហើយសូមកុំបាក់ទឹកចិត្ត។ អ្នកប្រហែលជាមិនអាចជ្រើសរើសថាអ្នកកើតមកដោយរបៀបណាពិតមែន ប៉ុន្តែអ្នកអាចអភិវឌ្ឍជំនាញណាមួយ ហើយធ្វើវាអោយបានល្អបំផុតទៅតាមលទ្ធភាពដែលខ្លួនមានក្នុងពេលនេះ។» **លោក មករា** បន្ថែម



# លើសពីពិការភាព

## សេចក្តីសោមនស្សក្នុងការទទួលបានការងារ

**STRIVING BEYOND DISABILITY**

*The Happiness in Having Employment*

ដំណើរឆ្ពោះទៅរកបរិយាបន្នការងារសម្រាប់ជនមានពិការភាព

Towards Inclusive Employment for People with Disabilities

Author : SATHYA Hato    Interviewer : YOU Sopheakphanith

# លើសពីពិការភាព : សេចក្ដីសោមនស្ស ក្នុងការទទួលបានការងារ



«ខ្ញុំទទួលបានឱកាសដែលជាការគាំទ្រដ៏ធំបំផុតសម្រាប់រូបខ្ញុំ។ ខ្ញុំតែងតែទទួលបានការមិនយកចិត្តទុកដាក់ ដោយសារតែពិការភាពរបស់ខ្ញុំ ប៉ុន្តែករណីនេះមិនបាន កើតឡើងនៅទីនេះទៀតទេ។ ខ្ញុំក៏មានទំនាក់ទំនងល្អជាមួយអ្នករួមការងារផងដែរ តាមរយៈការពន្យល់ណែនាំ និងផ្តល់ជំនួយប្រសិនបើខ្ញុំមានបញ្ហាផ្សេងៗ។» **លោក ហ៊ុល វ៉ាន់នីវុធ** ជំនួយការរដ្ឋបាល និងអ្នករចនាក្រាហ្វិកក្នុងក្រុមហ៊ុន SM Eco Development (SMED)

ស្ថិតនៅក្នុងអាយុ ៤០ឆ្នាំ **លោក ហ៊ុល វ៉ាន់នីវុធ** ជាបុគ្គលិកមានពិការភាពផ្នែកខាងក្រោមមានមុខតំណែងជាជំនួយការរដ្ឋបាល និងអ្នករចនាក្រាហ្វិកក្នុងក្រុមហ៊ុន SM Eco Development (SMED)។ ក្នុងពេលពេញមួយអាជីព លោកបានបំពេញការងារនៅក្នុងក្រុមហ៊ុនចំនួន ២កន្លែង និងបានអភិវឌ្ឍជំនាញផ្សេងទៀតដើម្បីបង្កើនប្រាក់ចំណូលបន្ថែមផងដែរ។ ជាក់ស្តែងជីវិតការងាររបស់លោក បានចាប់ផ្តើមនៅ «វិទ្យុសម្លេងជីវិតថ្មី» ដែលលោកទទួលបានឱកាសក្នុងតួនាទីជាអ្នកទទួលខុសត្រូវការចាក់ផ្សាយរយៈពេល ៤ឆ្នាំមុននឹងលោកផ្លាស់ទៅបំពេញការងារជាជំនួយការរដ្ឋបាលផ្នែកបណ្ណាល័យ អ្នកសម្របសម្រួលការបោះពុម្ព និងអ្នកបញ្ចូលសម្លេងនៅ «ព្រះបន្ទូលនៃជីវិត» រយៈពេល ៨ឆ្នាំទៀត។ **លោក វ៉ាន់នីវុធ** បានចាប់យកជំនាញ និងក្លាយជាអ្នកបច្ចេកទេសជួសជុលទូរស័ព្ទចាប់តាំងពីឆ្នាំ ២០១៦ រហូតមុនការកើតឡើងនូវការរាតត្បាតជាសកលនៃជំងឺកូវីដ ១៩។

ក្នុងនោះផងដែរជំនាញរចនាក្រាហ្វិក ជាជំនាញមួយទៀតដែលលោកបានចាប់យកហើយក្រោយមកក្លាយជាប្រភពចំណូលក្នុងអំឡុងពេលនោះ។ លោកមានចំណាប់អារម្មណ៍ចំពោះការងារបច្ចុប្បន្នរបស់ខ្លួន បន្ទាប់ពីទទួលដំណឹងតាមរយៈភរិយារបស់លោកពីការជ្រើសរើសបុគ្គលិកដែលមានពិការភាពរបស់អ្នកស្រី ឃួនសុជាតា ដែលជាសិក្ខាកាមរបស់សហគ្រាសសង្គម អ៊ែដ្យាយល៍ និងភរិយានាយកប្រតិបត្តិក្រុមហ៊ុន។

> «ខ្ញុំមានអារម្មណ៍ថាភ័យ ហើយនិយាយមិនចង់ចេញសោះ» **លោក វ៉ាន់នីវុធ** រៀបរាប់ពីអារម្មណ៍របស់ខ្លួនទៅលើការសម្ភាសន៍។

តាមរយៈការសម្ភាសន៍លើកទី ២ ក្នុងជីវិតការងារនេះលោកបានសារភាពថាលោកមិនដែលបញ្ចុះបញ្ចូលអ្នកជ្រើសរើសឱ្យទទួលយកពាក្យស្នើរសុំរបស់លោកនោះទេ។ លោកច្រើនតែដាក់ពាក្យ លុះត្រាតែមានការបើកឱកាសអោយជនដែលមានពិការភាព និងទៅសម្ភាសប្រសិនបើលោកជាប់ក្នុងវគ្គជម្រុះ។ ទោះបីជាមានពិការភាព លោកមានការប្តេជ្ញាចិត្តក្នុងការដាក់ពាក្យការងារនៅគ្រប់ស្ថាប័ន ឬក្រុមហ៊ុននានា។ ប៉ុន្តែតាមគំនិតផ្ទាល់ខ្លួន លោកគិតថាក្រុមហ៊ុន ឬស្ថាប័នទាំងនោះនឹងមានការលំបាកក្នុងការផ្តល់ឱកាសត្រលប់មកវិញដោយសារតែប្រភេទភារកិច្ចដែលត្រូវបែងចែក និងពិការភាពរបស់លោក។ ចំពោះការគាំទ្រនានា លោកក៏បានទទួលការសម្របសម្រួលមួយចំនួនក្នុងពេលសម្ភាសន៍ផងដែរ។ ជាឧទាហរណ៍ លោកទទួលបានការសម្របសម្រួលទៅលើការធ្វើដំណើរពីបុគ្គលមួយចំនួនបន្ទាប់ពីគេបានឃើញភាពលំបាករបស់លោក។ ទោះជាយ៉ាងណា លោករមែងច្រានចោលការសម្របសម្រួលទាំងនោះ ដោយហេតុថាវានឹងបង្កើនឧបសគ្គជាងការដែលលោកធ្វើដំណើរដោយខ្លួនឯង។

បន្ទាប់ពីបំពេញការងារនៅក្រុមហ៊ុន **SM Eco Development (SMED)** អស់រយៈពេលជិត ៤ខែមក លោកបានបង្ហាញពីភាពរីករាយរបស់ខ្លួនចំពោះការងារ ព្រមទាំងបានរៀបរាប់ពីភាពស្រដៀងគ្នារវាងមុខតំណែងចាស់ និងបច្ចុប្បន្នផងដែរ។

> «អ្វីដែលក្រុមហ៊ុនកំពុងផ្តល់ជូនទីផ្សារ ធ្វើឱ្យខ្ញុំនឹកឃើញពីក្តីស្រមៃរបស់ខ្ញុំពេលវ័យជំទង់។ ខ្ញុំធ្លាប់ស្រមៃថា ខ្ញុំចង់មានដីមួយកន្លែងដែលអាចសង់ផ្ទះនៅខាងមុខ និងដាំដំណាំបាននៅខាងក្រោយ ហើយឥឡូវខ្ញុំកំពុងធ្វើការនៅក្រុមហ៊ុនដែលផ្តល់អចលនទ្រព្យបែបនេះ» **លោក វ៉ាន់នីវុធ** បន្ថែម។

លោកបានអោយដឹងទៀតថា លោកពិតជាមានភាពរីករាយ និងទទួលបានអារម្មណ៍កក់ក្តៅចំពោះការងារបច្ចុប្បន្ន របស់លោកជាខ្លាំងបន្ទាប់ពីផ្អាកការប្រកបការងារអស់មួយរយៈពេលកន្លងមក។ លោកមានសិទ្ធគ្រប់គ្រាន់ក្នុងការចែករំលែកយោបល់ផ្ទាល់ខ្លួន ប្រសិនបើលោកមានកង្វល់ណាមួយព្រមទាំងអាចបំពេញរាល់កិច្ចការដែលបានចាត់តាំង។ ម៉្យាងវិញទៀត ក្រុមហ៊ុនក៏បានធ្វើការផ្លាស់ប្តូរហេដ្ឋារចនាសម្ព័ន្ធរូបវន្តមួយចំនួនបន្ទាប់ពីលោកចូលបំពេញការងារផងដែរ។ ដោយសារតែក្រុមហ៊ុនមានទីស្នាក់ការនៅតាមផ្លូវរថភ្លើងឆ្លងកាត់ តំណាងក្រុមហ៊ុនបានធ្វើការសាកសួរ និងកែតម្រូវផ្លូវធ្វើដំណើរដើម្បីសម្របសម្រួលដល់លោកបន្ថែមទៀត។

លើសពីនេះ ក្រុមហ៊ុនបានសាងសង់ជំរាលបន្ទប់ទឹកព្រមទាំងជួសជុលផ្ទះបាយ។ **លោក វ៉ាន់នីវុធ** បានបន្ថែមថាសម្ភារៈការិយាល័យដូចជាតុ និងកៅអីមានសភាពរឹងមាំដែលអាចជាបង្អែកសម្រាប់បុគ្គលិកដែលមានពិការភាពបាន។លោកក៏បានរំលឹកពីបទពិសោធន៍ដែលលោកទទួលបានការសម្របសម្រួលដែលល្អឥតខ្ចោះពីអ្នកគ្រប់គ្រងទូទៅអំឡុងពេលចុះពិនិត្យទីតាំងផងដែរ។ ដោយសារតែអស្ថិរភាពនៃអាកាសធាតុ ប្រធានគ្រប់គ្រងតែងសាកសួរពីផាសុកភាពរបស់លោកជារឿយៗព្រមទាំងបានលើកទឹកចិត្តក្នុងការត្រឡប់មកទីស្នាក់ការវិញទៀតផង។ ទោះជាយ៉ាងណា លោកនៅតែទទូចទៅដល់គោលដៅដូច្នេះប្រធានគ្រប់គ្រងក៏បានស្វែងរកមធ្យោបាយធ្វើដំណើរផ្សេងៗដើម្បីសម្រួលដល់លោក។

**លោក វ៉ាន់នីរ៉ុធ** បានសម្តែងការដឹងគុណចំពោះក្រុមហ៊ុនថា

> «ខ្ញុំទទួលបានឱកាសដែលជាការគាំទ្រដ៏ធំបំផុតសម្រាប់រូបខ្ញុំ។ ខ្ញុំតែងតែទទួលបានការមិនយកចិត្តទុកដាក់ដោយសារតែពិការភាពរបស់ខ្ញុំ ប៉ុន្តែករណីនេះ មិនបានកើតឡើងនៅទីនេះទៀតទេ។ ខ្ញុំក៏មានទំនាក់ទំនងល្អជាមួយអ្នករួមការងារផងដែរ តាមរយៈការពន្យល់ណែនាំ និងផ្តល់ជំនួយប្រសិនបើខ្ញុំមានបញ្ហាផ្សេងៗ» **លោក វ៉ាន់នីរ៉ុធ** បន្ថែម។

ដើម្បីអភិវឌ្ឍខ្លួនឱ្យក្លាយជាបុគ្គលិកដែលមានសមត្ថភាព លោកចង់ពង្រីកចំណេះដឹងបន្ថែមទៀតអំពីការធ្វើអាជីវកម្មលើប្រព័ន្ធអ៊ីនធើណេត (E-Commerce)។ ក្នុងនាមជាជនដែលមានពិការភាពម្នាក់ **លោក វ៉ាន់នីរ៉ុធ** សូមធ្វើការតស៊ូមតិលើបរិយាបន្នការងារបន្ថែមទៀតសម្រាប់ជនមានពិការភាព និងក្រើនរំលឹកដល់បុគ្គលិកដែលមានពិការភាពនានាអោយខិតខំលះបង់អោយអស់ពីសមត្ថភាព និងប្តេជ្ញាចំពោះការងាររបស់ខ្លួនទោះបីជាមានភាពនឿយហត់ ឬបាក់ទឹកចិត្តយ៉ាងណាក្តី។

> «គ្មានការងារណាដែលងាយស្រួលនោះទេ ដូច្នេះអ្នកត្រូវតែខិតខំប្រឹងប្រែងព្យាយាម ព្រោះយើងមិនងាយនឹងទទួលបានឱកាសបែបនេះទេ» **លោក វ៉ាន់នីរ៉ុធ** បន្ថែម។

---

ករណីសិក្សានេះធ្វើឡើងដោយសហគ្រាសសង្គម អ៊ែជ្យាលយ៍ ដែលជាផ្នែកមួយនៃយុទ្ធការលើកកម្ពស់ការយល់ដឹងស្តីពីការអនុវត្តបរិយាបន្នការងារសម្រាប់នយោជកនិងសមាគមន៍ដើម្បីបង្កើនការយល់ដឹងអោយកាន់តែស៊ីជម្រៅនូវតម្រូវការរបស់ជនមានពិការភាពតាមរយ:គម្រោង “ដំណើរឈ្មោះទៅរកបរិយាបន្នការងារសម្រាប់ជនមានពិការភាព” រយ:ពេលពន្ឆាំ (2021–2023) សហការអនុវត្តដោយអង្គការ ភីបផលអ៊ិននីតកម្ពុជា (People In Need Cambodia) និងសហគ្រាសសង្គម អ៊ែជ្យាលយ៍ (Agile Development Group) តាមរយ:ជំនួយឧបត្ថម្ភពីទីភ្នាក់ងារអភិវឌ្ឍន៍សាធារណ:រដ្ឋឆែក ដែលនឹងរួមចំណែកដល់ការបង្កើនលទ្ធភាព និងឱកាសការងាររបស់ជនមានពិការភាពនៅកម្ពុជាស្របតាម SDG4។

---

## ឧបសម្ព័ន្ធទី ១ បញ្ជីស្ថាប័នដែលធ្វើការលើពិការភាពនៅកម្ពុជា

| ស្ថាប័ន | ព័ត៌មានទំនាក់ទំនង | តួនាទី/សេវាកម្មដែលផ្តល់[2] |
|---|---|---|
| **អង្គការជនពិការជាតិនៅកម្ពុជា** | | |
| អង្គការជនពិការកម្ពុជា (CDPO) | អ៊ីមែល៖ admin@cdpo.org<br>គេហទំព័រ៖ www.cdpo.org<br>ទូរស័ព្ទ៖ ០២៣ ២២១ ៨២៣<br>ទំព័រហ្វេសប៊ុក៖<br>https://www.facebook.com/cdpo.org<br>Youtube:<br>http://www.youtube.com/user/cdpocambodia | តួនាទីសំខាន់ក្នុងការតំណាងឱ្យទស្សនៈរបស់ជនពិការចំពោះស្ថាប័នរដ្ឋាភិបាលដែលជាផ្នែកមួយនៃដំណើរការគោលនយោបាយ<br>លើកកម្ពស់តម្រូវការរបស់ជនមានពិការភាពសម្រាប់ការបង្កលក្ខណ:ងាយស្រួល<br>និងសេវាកម្មប្រកបដោយបរិយាបន្ន។ |
| នាយកដ្ឋានសុខុមាលភាពជនពិការ<br>នៃក្រសួងសង្គមកិច្ច<br>អតីតយុទ្ធជន | លេខទូរស័ព្ទបន្ទាន់សម្រាប់បញ្ហាពិការភាព៖ ១២៧០<br>អ៊ីមែល៖ jobs.dwpd@gmail.com<br>ទូរស័ព្ទ៖ ០១៦ ៥៥៩ ៩១៧ | ដឹកនាំនិងគ្រប់គ្រង<br>ការងារទាក់ទងនឹងពិការភាព<br>ដើម្បីលើកកម្ពស់សិទ្ធិជនពិការ។ |

[2] cambodia-national-disability-strategic-plan-2014-18.pdf (unesco.org)

| | | |
|---|---|---|
| និងយុវនីតិសម្បទា<br>(MoSVY) | ទំព័រហ្វេសប៊ុក៖<br>https://www.facebook.com/wpdcambodia | |
| ក្រុមប្រឹក្សាសកម្មភាពជនពិការ<br>នៃក្រសួងសង្គមកិច្ច<br>អតីតយុទ្ធជន<br>និងយុវនីតិសម្បទា<br>(MoSVY) | អ៊ីមែល៖ dac@dac.org.kh<br>គេហទំព័រ៖ www.dac.gov.kh<br>ទូរស័ព្ទ៖ (៨៥៥)២៣ ៧២៧ ៩២៨<br>ទូរសារ៖ (៨៥៥)២៣ ៧២៧ ៩២៦<br>Facebook page:<br>https://www.facebook.com/DACCambodia | បង្កើតយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិទាក់ទងនឹងពិការភាព និងមានតួនាទីជំរុញការអនុវត្ត ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ ផែនការជាតិ ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗទាក់ទងនឹង ពិការភាព និងការស្តារនីតិសម្បទា។ |
| មូលនិធិជនពិការ<br>(PWDF) | អ៊ីមែល: pwdf@pwdf.gov.kh<br>គេហទំព័រ៖ www.pwdf.gov.kh<br>ទូរស័ព្ទ៖ ០២៣ ៩៨២ ៣០៦<br>ទំព័រហ្វេសប៊ុក៖<br>https://www.facebook.com/pwdf.pagelike/ | សាធារណៈរដ្ឋបាល ស្ថាប័នដែលមានភារកិច្ចបញ្ចេញថវិកាសម្រាប់គម្រោង និងការអនុវត្តកម្មវិធីដើម្បីជួយជនមានពិការភាព និងស្ថាប័នគាំទ្រដែលផ្តល់សេវាដល់ជនមានពិការភាព ដូចជា សុខភាព ស្តារនីតិសម្បទា ការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងការផ្តល់ការងារ។ |

| អង្គការផ្សេងទៀតដែលធ្វើការលើពិការភាព | | |
| --- | --- | --- |
| សកម្មភាពស្តីពីពិការភាព និងការអភិវឌ្ឍន៍ (ADD) កម្ពុជា។ | គេហទំព័រ៖ www.add.org.uk/cambodia<br>ទូរស័ព្ទ៖ ០២៣ ៨៨៥ ០០៦<br>Facebook page:<br>www.facebook.com/add.international.cambodia | ធ្វើការក្នុងភាពជាដៃគូជាមួយបណ្តាញនៃអង្គការជនមានពិការភាពដទៃទៀត ដើម្បីជួយពួកគេក្នុងយុទ្ធនាការបរិយាបន្នជនមានពិការភាព និងកុមារឱ្យបានត្រឹមត្រូវនៅក្នុងសង្គម។ |
| សហគ្រាសសង្គមអ៊ែជ្យាលយ៍ | អ៊ីមែល៖ info@agiledg.com<br>គេហទំព័រ៖ www.agiledg.com<br>ទូរស័ព្ទ៖ ០១៧ ៣៥០ ៥៩៩ / ០១៦ ៧០៨ ៨៩៨ / ០៨៨ ៧៣៣ ៩៩០២<br>ទំព័រហ្វេសប៊ុក៖<br>https://www.facebook.com/agiledg<br>Linkedin៖<br>https://www.linkedin.com/company/agiledg | សហគ្រាសដែលប្រើប្រាស់ការរចនាវត្ថុនៃដំណើរការសាកល្បងដើម្បីបង្កើតដំណោះ ស្រាយ និងឱកាសសម្រាប់ជនមានពិការភាព ការផ្តល់សេវាបណ្តុះបណ្តាលលើ ពត៌មាន វិទ្យាសហគ្រិនភាព និងការតស៊ូមតិស្របតាមតម្រូវការរបស់ជនមានពិការភាព។ |
| កម្មវិធីអភិវឌ្ឍន៍មនុស្ស ថ្លង់ (DDP) | អ៊ីមែល៖ info@ddp-cambodia.org<br>គេហទំព័រ៖ www.ddp-cambodia.org | ធ្វើការដើម្បីលុបបំបាត់ឧបសគ្គដែលរារាំងមនុស្សគថ្លង់ក្នុងប្រទេសកម្ពុជាពីការសម្រេចបានសម |

| | | |
|---|---|---|
| | ទូរស័ព្ទ៖ ០១៧ ៩៩៣ ៣២១<br>Facebook Page:<br>https://www.facebook.com/DDP.Cambodia | ភាព ដោយផ្តល់នូវការស្រាវជ្រាវ និងការអភិវឌ្ឍន៍ភាសាសញ្ញាកម្ពុជា វគ្គ បណ្តុះបណ្តាល និងការងារ សកម្មភាព អភិវឌ្ឍន៍សហគមន៍ សេវាបកប្រែភាសា សញ្ញាកម្ពុជា និងសេវាសង្គម។ |
| អង្គការបុគ្គលសារវន្ត កម្ពុជា(EPC) | អ៊ីមែល៖ nimulessential@gmail.com<br>ទូរស័ព្ទ៖ ០១២ ៣២៤ ៥៩៨<br>Facebook Page:<br>www.facebook.com/essentialpersonnelcambodia | ការផ្តល់សិទ្ធិអំណាចដល់យុវជនកម្ពុជាដែលមានពិការភាពតាមរយៈការអប់រំ និងការ បណ្តុះបណ្តាលវិជ្ជាជីវៈ ឈានទៅរកការងារ និងឯករាជ្យភាព។ |
| អង្គការមិត្តសំឡាញ់ | អ៊ីមែល៖ info@mithsamlanh.org<br>គេហទំព័រ៖ www.mithsamlanh.org<br>ទូរស័ព្ទ៖ ០២៣ ២២០ ៥៩៦ | ធ្វើការជាមួយកុមារ/យុវជនដែលខ្វះខាត ដើម្បីជួយសម្រួលដល់សមាហរណកម្ម សង្គមរបស់កុមារទៅក្នុងគ្រួសាររបស់ពួកគេ ប្រព័ន្ធសាលារៀនសាធារណៈ កន្លែងធ្វើការ និងវប្បធម៌របស់ពួកគេ។ |
| អង្គការសកម្មភាព ប្រជាជនដើម្បីអភិវឌ្ឍន បរិយាបន្ន (PAfiD) | អ៊ីមែល៖ info@pafid.local<br>គេហទំព័រ៖ www.pafid.org<br>ទំព័រហ្វេសប៊ុក៖ | ផ្តោតលើការអភិវឌ្ឍន៍បរិយាបន្នសហគមន៍ ដោយធ្វើការដោយផ្ទាល់ជាមួយក្រុមដែល ងាយរងគ្រោះបំផុតមួយចំនួន ដូចជាជនមាន ពិការភាព |

| | | |
|---|---|---|
| | https://www.facebook.com/PAfID.org | ដើម្បីធានាថាពួកគេអាចទទួល បានសិទ្ធិ និងសក្តានុពលរបស់ពួកគេ។ |
| មជ្ឈមណ្ឌលភ្នំពេញសម្រាប់ការរស់នៅឯករាជ្យ (PPCIL) | អ៊ីមែល៖ info@ppcil.org<br>គេហទំព័រ៖ www.ppcil.org<br>ទូរស័ព្ទ/ទូរសារ៖ ០២៣ ៦៣២៥ ២១៤<br>ទូរស័ព្ទ៖ ០៧៧ ៥០០ ៧០៦ | ផ្តល់ឱ្យជនមានពិការភាពនូវការបណ្តុះបណ្តាល ឧបករណ៍ប្រើប្រាស់ ការលើកទឹកចិត្ត និងជំនួយដែលត្រូវការ ដើម្បីអនុញ្ញាតឱ្យពួកគេរស់នៅដោយឯករាជ្យ។ |

# ឯកសារយោង

Better Work Indonesia. (2014, October 09). *Employing Persons With Disabilities: Guideline for Employers*. Better Work Indonesia.

Corporate Finance Institute. (2022, 12 07). *Memorandum of Understanding (MOU)*. CFI Education Inc. Retrieved 02 02, 2023, from https://corporatefinanceinstitute.com/resources/valuation/memorandum-of-understanding-mou/

The Diversity Trust. (n.d.). *Accessibility Audit*. The Diversity Trust: Influencing Social Change. Retrieved 02 01, 2023, from https://www.diversitytrust.org.uk/accessibility-audit/

International Labour Organization. (2016). Including Persons with Disabilities in Technical and Vocational Education and Training. In *A Guide for Administrators and Instructors to Disability Inclusion* (p. 10). International Labour Organization. https://www.ilo.org/wcmsp5/groups/public/---asia/---ro-bangkok/---ilo-dhaka/documents/publication/wcms_543304.pdf

International Labour Organization. (2017). *Policy Brief: Making TVET and skills system inclusive of persons with disabilities*. https://www.ilo.org/wcmsp5/groups/public/---ed_emp/---ifp_skills/documents/publication/wcms_605087.pdf

Merriam Webster. (2023, April 16). *Inclusive Definition & Meaning*. Merriam-Webster. Retrieved April 19, 2023, from https://www.merriam-webster.com/dictionary/inclusive

Microsft. (n.d.). *Disability Hiring | Global Diversity and Inclusion at Microsoft*. Microsoft. Retrieved April 19, 2023, from https://www.microsoft.com/en-us/diversity/inside-microsoft/cross-disability/disabilityhiring

Microsoft Corporate Blogs. (2022, February 8). *Highlighting innovations, maximizing inclusive practices and overcoming barriers to employment for people with disabilities - Microsoft On the Issues*. The Official Microsoft Blog. Retrieved April 21, 2023, from https://blogs.microsoft.com/on-the-issues/2022/02/08/accessibility-us-senate-committee-health-hearing/

Ministry of Social Affairs, Veterans and Youth Rehabilitation. (2018). *Strategic Plan on Sectorial Development of Social Affairs, Veterans and Youth Rehabilitation 2019-2023*. Ministry of Social Affairs, Veterans and Youth Rehabilitation.

Pedulla, D. (2020, May 12). *Diversity and Inclusion Efforts That Really Work*. Harvard Business Review. Retrieved October 02, 2023, from https://hbr.org/2020/05/diversity-and-inclusion-efforts-that-really-work

The Professional Fellowship Program. (n.d.). *Inclusive Employment*. PFP-IDE Fellowship. Retrieved April 19, 2023, from https://pfp-idefellowship.org/about-fellowship-in-us/inclusive-employment/

Skills for Youth Employment in the Caribbean. (2021, September). A Road Map for Inclusive TVET 'Going for the Gold Standard'. In *Strategies for the Inclusion of Persons with Disabilities in Technical, Vocational Education and Training* (p. 12). Skills for Youth Employment in the Caribbean. https://www.skyecaribbean.com/wp-content/uploads/20211028-SkYE-Strategic-Road-Map-for-Inclusive-TVET-System.pdf

UNESCO. (2013). *Policy Review of TVET in Cambodia*. UNESCO. Retrieved March 29, 2023, from https://unesdoc.unesco.org/in/documentViewer.xhtml?v=2.1.196&id=p::usmarcdef_0000225360&file=/in/rest/annotationSVC/DownloadWatermarkedAttachment/attach_import_2

5536d22-a57a-4608-ba00-b31d71137cea%3F_%3D225360eng.pdf&locale=en&multi=true&ark=/ark:/48223/pf

UNESCO. (2013). *Policy Review of TVET in Cambodia*. UNESCO. Retrieved March 29, 2023, from https://unesdoc.unesco.org/in/documentViewer.xhtml?v=2.1.196&id=p::usmarcdef_0000225360&file=/in/rest/annotationSVC/DownloadWatermarkedAttachment/attach_import_25536d22-a57a-4608-ba00-b31d71137cea%3F_%3D225360eng.pdf&locale=en&multi=true&ark=/ark:/48223/pf

UNESCO. (2013). *Policy Review of TVET in Cambodia*. Retrieved March 29, 2023, from https://unesdoc.unesco.org/in/documentViewer.xhtml?v=2.1.196&id=p::usmarcdef_0000225360&file=/in/rest/annotationSVC/DownloadWatermarkedAttachment/attach_import_25536d22-a57a-4608-ba00-b31d71137cea%3F_%3D225360eng.pdf&locale=en&multi=true&ark=/ark:/48223/pf

UNESCO. (2013). *Policy Review of TVET in Cambodia*. UNESCO. Retrieved March 29, 2023, from https://unesdoc.unesco.org/in/documentViewer.xhtml?v=2.1.196&id=p::usmarcdef_0000225360&file=/in/rest/annotationSVC/DownloadWatermarkedAttachment/attach_import_25536d22-a57a-4608-ba00-b31d71137cea%3F_%3D225360eng.pdf&locale=en&multi=true&ark=/ark:/48223/pf

UNESCO. (2020, June). *TVET Country Profile: Cambodia*. UNESCO. Retrieved March 29, 2023, from https://unesdoc.unesco.org/ark:/48223/pf0000373699?locale=en

UNESCO. (2020, June). *TVET Country Profile: Cambodia*. UNESCO. Retrieved March 29, 2023, from https://unesdoc.unesco.org/ark:/48223/pf0000373699?locale=en

UNESCO. (2020, June). *TVET Country Profile: Cambodia*. UNESCO. Retrieved March 29, 2023, from https://unesdoc.unesco.org/ark:/48223/pf0000373699?locale=en

United Nations. (2006). *Convention on the Rights of Persons with Disabilities and Optional Protocol*. United Nations.

United Nations. (2019). *Disability-Inclusive Language Guidelines*. United Nations. https://www.ungeneva.org/sites/default/files/2021-01/Disability-Inclusive-Language-Guidelines.pdf

United Nations Department of Economic and Social Affairs Disability. (2008, 05 03). *Convention on the Rights of Persons with Disabilities (CRPD)*. United Nations Department of Economic and Social Affairs Disability. Retrieved 04 21, 2023, from https://www.un.org/development/desa/disabilities/convention-on-the-rights-of-persons-with-disabilities/article-27-work-and-employment.html

United Nations High Commissioner for Refugees. (n.d.). *Inclusive Budgeting Tip Sheet*. United Nations High Commissioner for Refugees. Retrieved 02 01, 2023, from https://www.unhcr.org/62962a0a4.pdf